February-2010.qxd 6/10/2010 2:46 PM Page 1


# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៣ ថ្ងៃទី០១-២៨ ខែកុម្ភៈ ឆ្នាំ២០១០ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ៣០


ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

## មាតិកា




បើស្នេហាពិត តើយុវជនគួររង់ចាំឬ? ទំព័រ ៥





បវរកញ្ញាមីនៈ "បើកាយពីការទៅ ហើយសូមកុំពិការចិត្ត" ទំព័រ ៩





កំណាយស្ថានីយបុរាណ ទំព័រ ១៧


# ស្ថានភាពចរាចរណ៍ផ្លូវគោកនៅកម្ពុជាកំពុងតែប្រសើរឡើង



ច្បាប់ចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានចូលជាធរមានចាប់តាំងពីថ្ងៃព្រះមហាក្សត្រឡាយព្រះហស្ថលេខាកាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០៧។ ចាប់តាំងពីពេលប៉ូលីសចរាចរណ៍បានចេញនូវវិធានការជាច្រើនដើម្បីទប់ស្កាត់បទល្មើសផ្សេងៗ។ តើស្ថានភាពចរាចរណ៍សព្វថ្ងៃ មានសភាពយ៉ាងណា? ទំព័រទី១០_១១


CSC .Net FAST INTERNET

SPECIAL DISCOUNT FOR STUDENTS
Only 600 Riels / hour !

Please bring your student's ID when coming for the first time.

Turn the card to see us on the map !

#25, St. 242, Boeng Prolet, 7Makara, Phnom Penh
Tel : (855)92 737 255 or (855)23 224 120
Monday to Friday : 7h30 - 21h Sat. & Sunday : 8h - 21h


កម្មវិធីវិទ្យុ



**អេម៉ានូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !

ភ្នំពេញ : **FM 102.5 Mhz** ម៉ោង២:០០-៣:០០ រាល់រសៀលថ្ងៃសុក្រ
បាត់ដំបង : **FM 91.0 Mhz** ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: **FM 102.5 Mhz** ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
កំពង់ធំ : **FM 88.5 Mhz** ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : **FM 100.5 Mhz** ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : **FM 100.5 Mhz** ម៉ោង៦:០០-៧:០០ យប់ថ្ងៃសៅរ៍
កំពត : **FM 93.25 Mhz** ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

# សារលិខិត

## លិខិតជ្រើសតាំងលោកអភិបាលឧបត្ថម្ភកៈ នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ



Photo : L. Sovanna

សម្តេចប៉ាប បេណេឌិក ទី១៦ បានជ្រើសតាំងលោកបូជាចារ្យ អូលីវីយេ ជ្មិតហ្សស្លេ នៃក្រុមសាសនទូត ក្រៅប្រទេសក្រុងប៉ារីសដែលជាតំណាងពេញសិទ្ធិលោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ និងជាលេខាក្រុមលោកអភិបាលនៅប្រទេសកម្ពុជាជាអភិបាលឧបត្ថម្ភកៈនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ លោកត្រូវបានតែងតាំងក្នុង តំណែងជាលោកនៃភូមិភាគ កាតាប៊ូម កាស្ត្រា។

លោកបូជាចារ្យអូលីវីយេ ជ្មិតហ្សស្លេ កើតនៅថ្ងៃទី២៦ មិថុនា ១៩៧០ នៅតំបន់ស្ត្រាសប៊ួ ប្រទេសបារាំង។ លោកបានបញ្ចប់សិក្សាការចំណេះដឹងទូទៅ បានចូលទេវវិទ្យាល័យ និងបានបញ្ចប់ការទស្សនវិជ្ជា និងទេវវិទ្យានៅសកលវិទ្យាល័យកាតូលិកនៅស្ត្រាសប៊ួ ប្រទេសបារាំង។ ពីឆ្នាំ១៩៩១-១៩៩៤ លោកធ្វើជាអ្នកស្ម័គ្រចិត្តនៅសកលវិទ្យាល័យសន្តថូម៉ាស នៅអូសាកា ប្រទេសជប៉ុន។ ថ្ងៃទី២៨ មិថុនា ១៩៩៨ លោកត្រូវបានតែងតាំងជាបូជាចារ្យ ក្នុង ក្រុមសាសនទូតក្រៅប្រទេសក្រុងប៉ារីស។

**មុខងារទទួលខុសត្រូវក្រោយទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ**

| | | |
|---|---|---|
| **ពីឆ្នាំ១៩៩៨-២០០២** | : | រៀនភាសាខ្មែរ។ |
| **ពីឆ្នាំ២០០២** | : | លោកទទួលខុសត្រូវនៅមណ្ឌលសកម្មភាពព្រះសហគមន៍តាកែវ និងកំពត។ |
| **ពីឆ្នាំ២០០២** | : | លោកជាប្រធានគណៈកម្មាការអប់រំចំណេះទូទៅ នៅព្រះសហគមន៍ភូមិភាគភ្នំពេញ។ |
| **ពីឆ្នាំ២០០៣-២០០៥** | : | ជាសាស្ត្រាចារ្យ ប្រវត្តិសាស្ត្រព្រះសហគមន៍ នៅទេវវិទ្យាល័យសន្តយ៉ូហានមារី វីយ៉ាណេ នាទីក្រុងភ្នំពេញ។ |
| **ពីឆ្នាំ២០០៧** | : | ជាតំណាងពេញសិទ្ធិលោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ។ |

# វិចារណកថា

## ព្រះយេស៊ូ គឺជាផ្លូវ និងជាជីវិត (លូកា ១:១១)



លោកប៉ូលរឿង ឆត្រឆ័យ អ្នកសម្របសម្រួលមណ្ឌលផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក (CSC)

បងប្អូនជាទីស្រឡាញ់! នៅប្រទេសថៃដែលមានប្រពៃណីជាតិដូចស្រុកខ្មែរយើង តែងតែមានការព្រួយបារម្ភជានិច្ចរឿងគ្រោះថ្នាក់ចរាចរណ៍នៅពេលបុណ្យធំៗ ដូចជា បុណ្យចូលឆ្នាំជាតិ និងបុណ្យចូលឆ្នាំសកល។ ដូច្នេះហើយ គេមានគម្រោងជាច្រើនដើម្បីបន្ថយគ្រោះថ្នាក់ ដូចជា មានកន្លែងត្រួតពិនិត្យតាមដងផ្លូវ ផ្តល់សេវាកម្មត្រួតពិនិត្យយានជំនិះដោយឥតគិតថ្លៃ ពិនិត្យជាតិអាកុល ចាប់ផាកពិន័យ ឬដាក់ទោសធ្វើពលកម្មសង្គម ពេលមានកំហុសខុសច្បាប់ចរាចរណ៍-ល-។

នៅពេលមានគ្រោះថ្នាក់ចរាចរណ៍ម្តងៗ ពុំគ្រាន់តែអ្នកធ្វើប្រហែសប៉ុណ្ណោះទេ ដែលរងគ្រោះ ប៉ុន្តែអ្នកដែលគ្មានកំហុស ឬសម្បត្តិសាធារណៈក៏រងគ្រោះខូចខាតដែរ។ ចំពោះគ្រីស្តបរិស័ទ ជនណាធ្វើប្រហែសអ្នកនោះខ្វះនូវសេចក្តីស្រឡាញ់ និងជាប់បាបដែរ ដូចជាការបើកបរដោយពុំគោរពច្បាប់ចរាចរណ៍ ហើយកាន់តែបាបធ្ងន់ថែមទៀត ប្រសិនមានចេតនាធ្វើឱ្យអ្នកដទៃរងគ្រោះថ្នាក់ ឬស្លាប់។

គ្រោះថ្នាក់សំខាន់មួយទៀត គឺការបណ្តោយជីវិត ខ្លួនឯងទៅតាមផ្លូវអាក្រក់ ឬនាំគ្រោះថ្នាក់មកកាន់ខ្លួនឯង គ្រួសារ ឬបងប្អូនអ្នកជិតខាង។ គ្រោះថ្នាក់នេះគឺអាក្រក់ជាងគ្រោះថ្នាក់ចរាចរណ៍ទៅទៀត ពីព្រោះផ្លូវចិត្តវិញ្ញាណអត់ល្អ គឺជាប្រភពអាក្រក់ដល់មនុស្សទាំងអស់ ដូចជាការចូលផ្លូវគ្រឿងញៀន ការមានចិត្តលោភលន់ ចង់បាន ចង់មាន ការមានចិត្តឆេវឆាវ និងការប្រើអំពើហិង្សា-ល-។

ព្រះយេស៊ូទុកព្រះអង្គផ្ទាល់ជាផ្លូវមួយដើម្បីយើងស្គាល់ផ្លូវសុភមង្គលក្នុងជីវិតគឺផ្លូវទៅកាន់ព្រះបិតា។ ព្រះអង្គបង្រៀនឱ្យមនុស្សមានចិត្តមេត្តាករុណា។

ព្រះសហគមន៍កាតូលិកក៏ខិតខំឆ្លើយតបតាមផ្លូវនេះ និងចង់ឱ្យមនុស្សទាំងអស់ផុតពីគ្រោះថ្នាក់ទាំងពួងដែរ។ ដូច្នេះនាឆ្នាំថ្មីនេះ សូមបងប្អូនយកចិត្តទុកដាក់លើការធ្វើដំណើរគ្រប់ទីកន្លែងឱ្យហ្មត់ចត់ត្រួតពិនិត្យយានជំនិះជាប្រចាំ និងគ្រប់ពេលវេលា ហើយជាពិសេសការធ្វើដំណើរខាងផ្លូវវិញ្ញាណផង!




## កម្មវិធីវិទ្យុព្រះសហគមន៍កាតូលិក

### អ្នកចូលរួមកម្មវិធីអេម៉ាន្ញូអែល "សម្លេងពីព្រះសហគមន៍កាតូលិក" ខែកុម្ភៈ

-ថ្ងៃអាទិត្យទី៥ រដូវធម្មតា (០៧ កុម្ភៈ) : លោកបូជាចារ្យប្រង់ស្វ័រ ប៉ុងស្វីមកពីក្រុមសាសនទូតក្រៅប្រទេសពីទីក្រុងប៉ារីស។

-ថ្ងៃអាទិត្យទី៦ រដូវធម្មតា (១៤ កុម្ភៈ) : លោកបូជាចារ្យអំរគី យ៉ាដុស មកពីក្រុមសាសនទូតក្រៅប្រទេសពីទីក្រុងប៉ារីស។

-ថ្ងៃអាទិត្យទី១ រដូវសែសិបថ្ងៃ (២១ កុម្ភៈ) : លោកបូជាចារ្យហេរ៉ាល់ មកពីក្រុមសាសនទូតក្រៅប្រទេសពីទីក្រុងប៉ារីស។

-ថ្ងៃអាទិត្យទី២ រដូវសែសិបថ្ងៃ (២៨ កុម្ភៈ) : បងស្រីកល្យាណមកពីក្រុមគ្រួសារបេះដូងព្រះនាងម៉ារី។

### "ខ្ញុំត្រូវការអ្នក" ខែកុម្ភៈ (FM 99.5 Mhz ចន្ទ,អង្គារ ម៉ោង១០-១១ព្រឹក)

ថ្ងៃទី០១ កុម្ភៈ : ចំណុចខ្សោយយុវវ័យក្នុងស្នេហា (បង្ហាញពីចំនុចអវិជ្ជមានដែលយុវវ័យចង់ប្រឡូកស្នេហា តែមិនទាន់ស្គាល់ និងគ្មានបទពិសោធន៍។ ចង់រត់ មុនចេះដើរ)។ ថ្ងៃទី០២ កុម្ភៈ : តម្លៃនារី បច្ចុប្បន្ន។ ថ្ងៃទី០៨-០៩ កុម្ភៈ : ស្នេហ៍ពិតបញ្ជាក់នៅថ្ងៃនៃសេចក្តីស្រឡាញ់ឬ ?។ ថ្ងៃទី១៥ កុម្ភៈ : យើងស្មោះគ្នាទេ ?។ ថ្ងៃទី១៦ កុម្ភៈ : គោលដៅស្នេហ៍។ ថ្ងៃទី២២ កុម្ភៈ : សុបិនស្នេហ៍។ ថ្ងៃទី២៣ កុម្ភៈ : កល់ល្បិចបញ្ចប់ស្នេហ៍។ សូមបញ្ជាក់ថា ប្រធានបទទាំងនេះនឹងមានការចូលរួមបកស្រាយពីវាគ្មិនដែលមានបទពិសោធន៍ និងជំនាញច្បាស់លាស់។**សូមកុំភ្លេចតាមដាន!**

**ការិយាល័យព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120;

E-mail : csccambodia@gmail.com

Website : www.catholiccambodia.org

អ្នកសម្របសម្រួល : លោកប៉ូលរឿង ឆត្រឆ័យ។ ប្រធាន : លោកលី សុវណ្ណា។

Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧

# សេដ្ឋកិច្ច

## មន្ត្រីអះអាងអំពីកំណើនផលនេសាទ

**ខាន់ ភីរម្យ**



Photo : S. Philong

ប្រធានរដ្ឋបាលជលផលបានអះអាងថា ទិន្នផលនេសាទត្រីទឹកសាប នៅដើមរដូវនេសាទ២០០៩-២០១០នេះ មានការកើនឡើង ។ ប៉ុន្តែប្រជាសហគមន៍នេសាទបានអះអាងថា ទិន្នផលកើនមែន តែមិនមែនដោយសារតែត្រីសម្បូរនោះទេ គឺដោយសារតែការចាប់កើនឡើងតែប៉ុណ្ណោះ ។

លោកណៅ ធួក ជាប្រធានរដ្ឋបាលជលផលបានត្រូវប្រព័ន្ធផ្សព្វផ្សាយដកស្រង់សំដីរបស់លោកនៅខណៈពេលដែលលោកចុះទៅស្វែងយល់ និងពិនិត្យការធ្វើអាជីវកម្មនេសាទទឹកសាបនៃប្រជានេសាទនៅក្នុងខេត្តពោធិ៍សាត់ថា ដើមរដូវនេសាទថ្មីនេះបង្ហាញថា ទិន្នផលត្រីទឹកសាប មានការកើនឡើងប្រមាណជា ២០% នេះបើគេប្រៀបធៀបនឹងរយៈពេល៣ខែដើមរដូវនេសាទឆ្នាំទៅ ។

ប្រភេទត្រីដែលរដ្ឋបាលជលផលសង្កេតឃើញថា មានការកើនឡើងគួរឱ្យកត់សម្គាល់នោះគឺមានប្រភេទត្រីឆ្ពោ ត្រីរ៉ស់ ត្រីកែស និងត្រីប្រម៉ា-ល-។ ពាក់ព័ន្ធនឹងកំណើននេះ លោកណៅ ធួក ក៏អះអាងថា មូលហេតុដែលទិន្នផលត្រីទឹកសាបឆ្នាំនេះ មានការកើនឡើង គឺដោយសារតែ នៅរដូវនេសាទឆ្នាំនេះ ទឹកជំនន់ទន្លេមេគង្គ គឺមានកម្ពស់ខ្ពស់ជាងឆ្នាំ២០០៨ ប្រមាណជា ០,៥៦ម ហើយរយៈពេលនៃការកើនឡើងកម្រិតទឹកនេះ គឺវាឡើងទាន់ពេលវេលា និងមានរយៈពេលយូរសមស្របសម្រាប់ការធំធាត់ និងការបង្កាត់ពូជរបស់ត្រី ហើយគួបផ្សំនឹងការខិតខំបង្ក្រាបបទល្មើសនេសាទផ្សេងៗ ពិសេសនៅរដូវត្រីពងកូន និងការខិតខំការការពារ និងថែរក្សាព្រៃលិចទឹកដែលជាដែនជម្រកត្រីពងកូន បានកាន់តែមានប្រសិទ្ធភាពទៀតនោះ ទើបធ្វើឱ្យបរិមាណទិន្នផលនេសាទមានការកើនឡើង ។

លោកជា សាន ប្រជាសហគមន៍នេសាទមួយរូបនៅក្នុងខេត្តពោធិ៍សាត់ មានប្រសាសន៍ទទួលស្គាល់ថា ទិន្នផលនេសាទពីបឹងទន្លេសាបពិតជាកើនឡើងមែន ។ ប៉ុន្តែកំណើននេះគឺមិនមែនដោយសារតែត្រីវាសម្បូរទេ គឺដោយសារតែប្រជានេសាទ គាត់ប្រើប្រាស់ឧបករណ៍ច្រើន និងខិតខំខ្លាំងជាងមុន ហើយចំនួនអ្នកនេសាទក៏កាន់ច្រើនទៀតនៅពេលនេះ ។ លោកបានលើកឡើងថា បច្ចុប្បន្ននេះយើងចំណាយពេលវេលា និងថវិកាច្រើនណាស់ដើម្បីធ្វើនេសាទ ហើយជួនកាលនេសាទត្រី អត់បានទៀតក៏មាន ។

### សហគមន៍នេសាទ

លោកណៅ ធួក មានប្រសាសន៍ថា រហូតមកដល់ពេលនេះ កម្ពុជាមានសហគមន៍ការពារត្រីមេពូជចំនួន ៣១៧សហគមន៍។

សហគមន៍ទាំងនោះកំពុងតែដើរតួនាទីជាកន្លែងស្តុក និងជាកន្លែងសុវត្ថិភាពចុងក្រោយរបស់ត្រីមេពូជឆ្នាំក្រោយ។ សម្រាប់នៅក្នុងខេត្តពោធិ៍សាត់នេះ គឺមានសហគមន៍ចំនួន៩ ហើយខាងរដ្ឋបាលជលផលបានយកត្រីគល់រាំងប្រភេទត្រីកម្រចំនួន ៣ក្បាល និងកូនត្រីមេពូជផ្សេងៗទៀតប្រមាណ ១៧៥០០០កូន នៅព្រៃវែង និងដាំកូនឈើលិចទឹកបានចំនួន ១២៥០០ដើម នៅក្នុងសហគមន៍ទាំងនេះ។

ទន្ទឹមនឹងការរក្សាដែនជម្រកនេះ លោកណៅ ធួក ក៏បានជំរុញឱ្យសហគមន៍ និងប្រជានេសាទទាំងអស់កុំប្រព្រឹត្តបទល្មើសជលផលនៅតាមមូលដ្ឋានរបស់ខ្លួន ដើម្បីជំរុញឱ្យការនេសាទមាននិរន្តរភាព។

# សុខភាព

## ការបរិច្ចាគឈាមជួយសង្គ្រោះជីវិតមនុស្ស គឺជាទង្វើមនុស្សធម៌

**ជាត សំភី**



Photo : Chimeng

បើតាមប្រសាសន៍របស់លោកថុក គឹមចេង ជានាយករងមជ្ឈមណ្ឌលជាតិផ្តល់ឈាមរបស់ក្រសួងសុខាភិបាលបានឱ្យដឹងថា:

អ្នកដែលអាចផ្តល់ឈាមបាន គឺប្រជាជនទូទៅទាំងអស់ ដែលមានអាយុចាប់ពី ១៧ឆ្នាំ រហូតដល់ ៦០ឆ្នាំ ហើយដែលគាត់មានសុខភាពល្អ គ្មាននូវជំងឺរ៉ាំរ៉ៃ និងមានលក្ខខណ្ឌស្របតាមគោលការណ៍ដែលគ្រូពេទ្យដែលគាត់ពិនិត្យមើលឃើញជាក់ស្តែង ។

លក្ខខណ្ឌមួយចំនួនដែលធ្វើឱ្យគាត់អាចបរិច្ចាគឈាមបាន : គាត់ត្រូវតែមានសុខភាពល្អដោយមិនប្រឈមមុខនឹងការឆ្លងមេរោគផ្សេងៗ ជាពិសេសជំងឺថ្លើម ឬជំងឺអេដស៍ ។ គាត់ក៏ត្រូវមានចំនួនគ្រាប់ឈាមគ្រប់គ្រាន់តាមលក្ខខណ្ឌ ។ និយាយជារួមគ្រូពេទ្យយកឈាមនឹងពិនិត្យឱ្យសមស្របតាមលក្ខខណ្ឌ និងបូមឈាមដោយពុំធ្វើឱ្យមានការប៉ះពាល់ដល់សុខភាពអ្នកផ្តល់នោះទេ ។

ប្រសិនបើប្រជាជន គាត់មានបំណងចង់បរិច្ចាគឈាម គាត់អាចទៅរកមជ្ឈមណ្ឌលជាតិផ្តល់ឈាមដែលមានទីតាំងនៅក្នុងមន្ទីរពេទ្យអង្គឌួង រាជធានីភ្នំពេញ និងនៅមន្ទីរពេទ្យគ្រប់ខេត្ត-ក្រុង ។ នៅទីនោះ គាត់អាចបរិច្ចាគឈាម ដោយមានសុវត្ថិភាពពីព្រោះសម្ភារៈមុតស្រួចសុទ្ធតែថ្មីៗ ។

លោកវេជ្ជបណ្ឌិតថុក គឹមចេង មានប្រសាសន៍ថា បើគាត់មានសុខភាពល្អ មិនមានជំងឺរ៉ាំរ៉ៃដូចជាលក្ខខណ្ឌដែលគ្រូពេទ្យជ្រើសរើស ១០០% នៃអ្នកផ្តល់ឈាមមិនទទួលផលលំបាកអ្វីទេ ។

ជាចុងក្រោយ លោកវេជ្ជបណ្ឌិតថុក គឹមចេង ក៏មានអនុសាសន៍ថា ប្រជាពលរដ្ឋទាំងអស់ សិស្ស ឬនិស្សិតគួរគិតគួរផ្តល់ឈាមដោយស្ម័គ្រចិត្ត ពីព្រោះវាគឺជាកិច្ចការមនុស្សធមិ ដែលអាចជួយសង្គ្រោះជីវិតមនុស្សបាននៅក្នុងសង្គម ។

February-2010.qxd 6/10/2010 2:47 PM Page 5






Photo : S. Philong

# បើស្នេហាពិត តើយុវជនគួររង់ចាំឬ?

**ខាន់ ភីរម្យ**

នេះជាសំណួរ ដែលកំពុងចោទនៅក្នុង ចំណោមស្រទាប់យុវវ័យសម័យបច្ចុប្បន្ននាខណៈពេលដែលមធ្យោបាយ និងប្រព័ន្ធទំនាក់ទំនងកំពុងបើកចំហ ។

ជាទូទៅបើទោះបីជារបាំងវប្បធម៌ ឬប្រពៃណីត្រូវបានគេទទួលស្គាល់ថា នៅតែមានឥទ្ធិពល នៅក្នុងការធ្វើសេចក្ដីសម្រេចចិត្តនៅលើបញ្ហាទំនាក់-ទំនងស្នេហារវាងបុរស និងនារីក៏ដោយ ។ ប៉ុន្តែឥទ្ធិ-ពលនៃការហូរចូលនូវវប្បធម៌បរទេស និងការបើកទូលាយសង្គមនោះ ក៏ធ្វើឱ្យបច្ចុប្បន្នភាពនៃសេចក្ដីស្នេហារបស់យុវជនខ្មែរ គឺហាក់ដូចជាកំពុងតែមានការប្រែប្រួលផងដែរ ។

យុវនិស្សិតមួយរូប ឈ្មោះរតនា ហើយបច្ចុប្បន្នជានិស្សិតនៅសកលវិទ្យាល័យធនធានមនុស្សបានអះអាងថា ជាទូទៅទំនាក់ទំនងស្នេហាក្នុងចំណោមស្រទាប់យុវវ័យនាពេលបច្ចុប្បន្ននេះ វាហាក់ដូចជាផុយស្រួយខ្លាំងណាស់ ។

រតនាក៏បានអះអាងថា: "ខ្ញុំឃើញមិត្តភក្តិរបស់ខ្ញុំខ្លះឧស្សាហ៍ដូរសង្សារណាស់ ។ អ៊ីចឹងហើយបានជាខ្ញុំគិតថា ស្នេហារបស់ពួកគេហាក់ ដូចជាមានភាពផុយស្រួយមែនទែន ។ ជួនកាលខ្ញុំឃើញ គេដឹកអ្នកនេះ ជួនកាលគេដឹកអ្នកនោះ ហើយក៏មកអួតខ្ញុំថា សុទ្ធតែជាសង្សារគេទាំងអស់ហ្នឹង" ។

តាមការអះអាងរបស់ រតនា ការស្វែងរកដៃគូស្នេហ៍ច្រើនបែបនេះហាក់ដូចជាមិនល្អសោះឡើយ ពីព្រោះ វប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីខ្មែរគឺហាក់ដូចជាមិនអនុញ្ញាតឱ្យពួកគេធ្វើបែបនេះទេ ។ ដូច្នេះបើសិនពួកគាត់គឺជាអ្នកដែលគោរពវប្បធម៌ និងប្រពៃណីខ្មែរ ពួកគេមិនគួរធ្វើបែបនេះឡើយ ។ ប្រពៃណី និងវប្បធម៌ខ្មែរ តែងតែអប់រំដល់យុវវ័យ និងយុវជនទាំងអស់ឱ្យមានភាពស្មោះត្រង់និងមានស្នេហាប្ដីមួយប្រពន្ធមួយ ។

គំនិតរបស់រតនាហាក់ដូចជាផ្ទុយនឹងគំនិតរបស់យុវជនមួយរូបផ្សេងទៀត ដែលអះអាងដោយមិនបញ្ចេញឈ្មោះថា ការទំនាក់ទំនងស្នេហាច្រើន គឺដើម្បីទទួលបានបទពិសោធន៍ជីវិតច្រើនដែរ ។ ប៉ុន្តែរូបគេទទួលស្គាល់គុណវិបត្តិនៃការបង្កទំនាក់ទំនងច្រើន ឬជ្រាលជ្រៅលើសពីស្នេហាធម្មតា ។

គាត់បញ្ជាក់ថា: "បើយើងទាក់ទងគ្នាធម្មតា ពុំស៊ីជម្រៅ ខ្ញុំគិតថាគ្មានអ្វីធ្ងន់ធ្ងរទេ ។ ប៉ុន្តែបើទំនាក់ទំនងនោះស៊ីជម្រៅ ហើយគ្រប់ភាគីអត់ជំទាស់ ក៏ពុំមានបញ្ហាដែរឱ្យតែយើងចេះប្រយ័ត្ន" ។

យុវជនរូបនោះក៏បានឱ្យដឹងទៀតដែរថា រហូតមកដល់ពេលនេះទំនាក់ទំនងស្នេហារវាងបុរស និងស្ត្រីកំពុងតែបើកចំហឡើងៗ ។ យុវជនរូបនេះ បានបន្តថា ការស្វែងរកសង្សានាពេលសព្វថ្ងៃនេះ មានរហូត ដល់ទៅប្រកាសលេខទូរស័ព្ទតាមវិទ្យុ តាមទស្សនាវដ្ដី និងខ្លះទៀត មានរហូតដល់តាមប្រព័ន្ធអ៊ីនធឺណិតទៀតផង ។

លោកជាង សុខា ប្រធានកម្មវិធីអភិវឌ្ឍន៍ធន-ធានយុវជនមានប្រសាសន៍ដែរថា សេចក្ដីស្រលាញ់ និងសេចក្ដីស្នេហា វាមិនមែនជាកំហុសរបស់យុវ-ជន ឬយុវនារីនោះទេ សំខាន់ឱ្យតែពួកគេ អាចចេះរៀបចំផែនការជីវិត មានការគោរព និងឱ្យតម្លៃគ្នា ហើយស្មោះត្រង់គ្នាទៅវិញទៅមក ។ លោកក៏បានបញ្ជាក់ថា: "សេចក្ដីស្នេហា ឬសេចក្ដីស្រលាញ់ គឺជាធម្មជាតិរបស់មនុស្សដែលយើងពុំគួរហាមឃាត់ តែយើងត្រូវចេះចាត់ចែងសេចក្ដីស្នេហារបស់យើងឱ្យបានច្បាស់លាស់" ។ លោកក៏បានបន្តទៀតថា បើយើងគោរពទៅតាមគោលការណ៍ខាងលើអស់នេះ បញ្ហាដែលកើតចេញពីសេចក្ដីស្នេហា ដូចជាការរួមភេទ ជំងឺសង្គម បញ្ហារំលូតកូនជាដើម នឹងមិនកើតមានឡើងងាយៗនោះទេ ។

## កសិកម្ម

# ដំណាំខែប្រាំង គឺជាសក្តានុពលមួយ

**ជាត សំភី**

លោកអ៊ី ណារុន មន្ត្រីគ្រប់គ្រងគម្រោងនៃមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជាសេដាក មានប្រសាសន៍ថា៖

បន្លែខែប្រាំង គឺជាពួកត្រូវការទឹកតិច ក្នុងនោះមានដូចជា ពពួកត្រប់គ្រប់ប្រភេទ សាលាដ ឃ្លោក ត្រឡាច ល្ពៅ ខ្ទឹម ជាដើម។ ចំណែកការដាំ វាមានរបៀបមួយចំនួនខុសពីការដាំ នៅរដូវវស្សា។ ការដាំនៅរដូវប្រាំង យើងត្រូវលើករងឱ្យទាបកុំឱ្យខ្ពស់ពេក និងមានដក់ទឹកនៅកណ្តាលគុម្ព។ម្យ៉ាងទៀត យើងត្រូវយកទន្រ្ទានខេត្ត មកគ្រប សម្រាប់ដំណាំយកដើម និងស្លឹក ក្រោយពេលដែលយើងស្ទូង កូនហើយ។ ប៉ុន្តែទោះជាយ៉ាងណាការដាំនៅរដូវប្រាំង កសិករត្រូវធ្វើនៅជិតប្រភពទឹកផងដែរដើម្បីងាយស្រួលយកមកស្រោចស្រព។

សម្រាប់ការដាំដំណាំ ចំនុចដែលសំខាន់ កសិករត្រូវពិនិត្យទៅលើគុណភាពដី។ ប្រសិនបើដីគាត់ពុំសូវមានជីជាតិ គាត់ត្រូវត្រៀមឱ្យហើយដូចជា ការស្វែងរកនូវជីធម្មជាតិមកប្រើប្រាស់ ក្នុងនោះមានជីកំប៉ុស្តទឹក និងជីកំប៉ុស្តគោកជាដើម។ បើពុំដូចនោះ គាត់អាចយកដី នៅក្រោមព្រៃ ដែលមានស្លឹកឈើជ្រុះធ្លាក់លើច្រើនមកដាក់បន្ថែមក៏បាន។



Photo : Y. Narun

ហើយដើម្បីងាយថែទាំកសិករគួរដាំដំណាំច្រើនមុខចម្រុះគ្នា ដូចជា ដំណាំយកមើម ដំណាំយកស្លឹក និងដំណាំយកដើម។ បើធ្វើដូច្នេះ កសិករគាត់អាចបន្ថយនូវកត្តាចង្រៃបំផ្លាញបាន និងអាចធានាទាញយកទិន្នផលបាន ពីព្រោះថា បើកត្តាចង្រៃបំផ្លាញមួយមុខ វាក៏នៅសល់មុខផ្សេងទៀតដែលអាចឱ្យផលបាន។ និយាយរួមការដាំដំណាំនៅរដូវប្រាំង វាមានសក្តានុពលជាងរដូវវស្សាផងឱ្យតែមានប្រភពទឹកគ្រប់គ្រាន់ ដី ជី កម្លាំងពលកម្ម ព្រមទាំងការថែទាំដែលប្រកបដោយការយកចិត្តទុកដាក់។

លោកអ៊ី ណារុន មានប្រសាសន៍ថា ការដាំបន្លែមិនទាមទារចំណាយពេលច្រើនទេ វាអាចប្រសើរជាជាងទៅធ្វើជាកម្មករដែលត្រូវធ្វើការ១២ម៉ោងលើ ១២ម៉ោង។ យើងគ្រាន់ចំណាយពេលមួយថ្ងៃ ២ម៉ោង ព្រឹកល្ងាចយើងក៏អាចបានផលច្រើនដែរ។

លោកផ្តល់អនុសាសន៍ទៀតថា កសិករត្រូវយកចិត្តទុកដាក់ដាំដំណាំ នៅរដូវប្រាំង។បើនិយាយឱ្យងាយ បើគាត់ដាំអ្វីបាន គាត់គួរតែដាំទៅ។ គាត់ធ្វើដូច្នេះយ៉ាងហោចណាស់ គាត់មានបន្លែទុកហូបនៅក្នុងគ្រួសារ ដោយមិនចាំបាច់ចំណាយប្រាក់ទិញ ឬទៅសុំគេខ្ទឹមមួយមើម ឬស្លឹកគ្រៃមួយគុម្ព។

## បរិស្ថាន

# សកម្មជនបរិស្ថានតវ៉ានៅទីក្រុងបាងកក

សកម្មជនបរិស្ថានមួយចំនួនបាននាំគ្នាកាន់បដាដើម្បីសម្តែងការតវ៉ារបស់ពួកគេនៅពីខាងក្រៅស្ថានទូតអាម៉េរិកនៅឯទីក្រុងបាងកក ប្រទេសថៃ



Photo : DR

ដោយចោទប្រកាន់ប្រទេសនេះថា បានធ្វើឱ្យបរាជ័យកិច្ចប្រឹងប្រែងថែរក្សាបរិស្ថានពិភពលោក។

ហើយទីភ្នាក់ងារព័ត៌មានបរទេសមួយចំនួន ក៏បានធ្វើការចោទប្រកាន់ប្រទេសផ្សេងៗទៀត ដូចជាកាណាដា និងអូស្ត្រាលីផងដែរ។

លោកវ៉ុន ហ្វីណាន់ដេ នាយកប្រតិបត្តិអង្គការហ្វ្រីនភីស ប្រចាំនៅតំបន់អាស៊ីអាគ្នេយ៍ បានអះអាងថា ប្រទេសបីនេះគឺជាប្រទេស ដែលត្រូវបានគេចាត់ទុកថា ជាអ្នកទទួលខុសត្រូវលើការបង្កើតបញ្ហាអាកាសធាតុនៅលើផែនដី។ តែពួកគេបានបដិសេធក្នុងការប្តេជ្ញាចិត្តខ្ពស់ដើម្បីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ស្របទៅតាមកម្រិតដែលត្រូវការដើម្បីទប់ទល់នឹងបម្រែបម្រួលអាកាសធាតុ។

នាបច្ចុប្បន្ននេះ ប្រទេសជាច្រើនរំពឹងអាម៉េរិកដើម្បីកាត់បន្ថយនូវការបំភាយឧស្ម័នកាបូនិកទៅក្នុងបរិយាកាស។ តែក្រុមសកម្មជនបរិស្ថាន បានអះអាងថា រដ្ឋាភិបាលអាម៉េរិកគឺហាក់ដូចជាយឺតយ៉ាវណាស់ក្នុងការរៀបចំច្បាប់ស្តីពីការកាត់បន្ថយនេះ។ ពាក់ព័ន្ធនឹងបញ្ហានេះ រដ្ឋាភិបាលអាម៉េរិកក្រោមការដឹកនាំពីលោកបារ៉ាក់ អូបាម៉ាបានសន្យាថា អាម៉េរិកនឹងកាត់បន្ថយលើការរីកសាយភាយឧស្ម័នកាបូនិចនេះឱ្យបាន១៧% នៅក្រោមកម្រិតបំភាយកាលពីឆ្នាំ២០០៥ ឱ្យបានមុនឆ្នាំ២០២០។

**ខាន់ ភីរម្យ**

February-2010.qxd 6/10/2010 2:47 PM Page 7



# មណ្ឌលបន្ទាយព្រាបបណ្តុះបណ្តាលជំនាញអេឡិចត្រូនិច

**ជាត សំភី**

ជំនាញអេឡិចត្រូនិចត្រូវ បានបង្កើតឡើងតាំងពីឆ្នាំ១៩៩៧ ដោយមណ្ឌលបន្ទាយព្រាប ដែលមានបណ្តុះបណ្តាលជំនាញ ជាច្រើនដល់ជនពិការកម្ពុជា ដោយសារគ្រាប់មីន និងប៉ូលីយ៉ូ។ មណ្ឌលនេះស្ថិតនៅក្នុងក្រោមការគ្រប់គ្រងរបស់អង្គការជេស្វីត-ស៊ុី កម្ពុជា នៅក្នុងភូមិត្រពាំងវែង ឃុំឆក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល។

លោកឃ្លៀង វ៉ាន់ នាយកសាលាបន្ទាយព្រាប មានប្រសាសន៍ថា: "ផ្នែកអេឡិចត្រូនិចនេះ គឺត្រូវបានបង្កើតឡើង ដោយសារយើងសិក្សាឃើញនៅលើទីផ្សារ មានអតិថិជនច្រើន។ ដូច្នេះសិស្សដែលរៀនចប់អាចងាយស្រួលរកការងារបានធ្វើ"។



Photos : Banteay Preab

**សិស្សពិការនៅសាលាបន្ទាយព្រាប ទោះបីជារាងកាយពិការ តែចិត្តមិនពិការ ខំរៀនជំនាញសម្រាប់អនាគត**

រហូតមកដល់សព្វថ្ងៃនេះ វគ្គអេឡិចត្រូនិចបានឈានចូលដល់វគ្គទី២៣ ហើយដែលមានសិស្សមកចូលរៀននៅ ឆ្នាំ២០១០នេះ ចំនួន ២៥នាក់ ហើយក្នុងមួយវគ្គៗ មានរយៈពេល ១ឆ្នាំ។ លោកឃ្លៀង វ៉ាន់មានប្រសាសន៍ថា លក្ខខណ្ឌរបស់យើងក្នុងការទទួលសិស្សឱ្យចូលរៀនក្នុងវគ្គនេះ គឺគេត្រូវជាជនពិការដែលមានលទ្ធភាពរៀន វាមានន័យថា ពិការជើង ម្ខាង ឬប៉ូលីយ៉ូ ហើយអ្នកក្រីក្រគឺជាអាទិភាពដំបូងគេ។ លោកបន្តថា ទោះជាយ៉ាងណា អេឡិច-ត្រូនិចនេះជាវគ្គពិសេសជាងគេ សិស្សត្រូវចេះអាន និងចេះសរសេរឱ្យបានច្បាស់លាស់ ពីព្រោះជំនាញនេះវាទាក់ទងនឹងទ្រឹស្តី ដែលត្រូវការកត់ត្រា។

សិស្សជំនាញអេឡិចត្រូនិចភាគច្រើនមកពីខេត្តផ្សេងៗ ដែលនៅជិតៗមានដូចជាក្រុងភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ តាកែវ កំពង់ចាម កំពង់ឆ្នាំង ព្រៃ-វែង ឬខេត្តសៀមរាប និងបាត់ដំបងដែលមានក្រុមការងារមណ្ឌលផ្ញើមក។ ចំណែកសិស្សផ្សេងពីនេះត្រូវបញ្ជូនមកតាមរយៈអង្គការជាដៃគូ។

លោកឃ្លៀង វ៉ាន់បានរៀបរាប់ឱ្យដឹងថា: "ការបណ្តុះបណ្តាលផ្នែកអេឡិចត្រូនិចជួបការលំបាកខ្លះដែរ ដោយសារកម្រិតចេះដឹងរបស់សិស្ស គឺមិនដូចគ្នា។ យើងតែងតែរកដំណោះស្រាយរហូត។ ប៉ុន្តែយើងមានកម្លាំងចិត្ត គឺដោយសារសិស្សរបស់យើងជាង ៨០% អាចរកការងារធ្វើបាន"។ លោកបន្តថា សម្រាប់គម្រោងទៅថ្ងៃមុខ យើងក៏មិនទាន់ដឹងច្បាស់លាស់ទេ។ យើងតែងធ្វើតាមទីផ្សារ។ ប៉ុន្តែពេលនេះ យើងកំពុងតែសិក្សាពីការបណ្តុះបណ្តាលជំនាញជួសជុលទូរស័ព្ទដែលមានការនិយម។

# អ៊ូ អ៊ីនដុន : "អប់រំគេឱ្យហ៊ានប្រឈមមុខនៅក្នុងសង្គម"

មណ្ឌលបន្ទាយព្រាបបង្កើតឡើងតាំងពីឆ្នាំ១៩-៩១។ តាំងពីជនភៀសខ្លួនដោយសារសង្គ្រាមចាប់ផ្តើមត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ ហើយពន្លឺសន្តិភាពចាប់មានវិញ ក្រុមជេស្វិតបានសម្រេចចិត្តជួយជនពិការ ដោយសារសង្គ្រាមនៅកម្ពុជា ដែលប្រហែលជាប្រទេស ដែលមានជនពិការច្រើនជាងគេនៅក្នុងតំបន់។ ដូច្នេះការបង្កើតមណ្ឌលបណ្តុះ-បណ្តាលវិជ្ជាជីវៈ គឺជាជម្រើសមួយ។

លោកបូជាចារ្យអ៊ូ អ៊ីនដុន គឺជាប្រធានមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការបន្ទាយព្រាប មានប្រសាសន៍ថា : "យើងបានបង្កើតមណ្ឌលនេះឡើងដើម្បីជួយជនពិការដែលជាជនងាយរងគ្រោះក្នុងសង្គម។ យើងជួយពួកគេទាំងស្មារតី និងផ្លូវចិត្ត-តាមរយៈការបណ្តុះបណ្តាលជំនាញ។ ក្រោយមកពួកគេអាចហ៊ានប្រឈមមុខនៅក្នុងសង្គមនិងអាចហ៊ានទៅរកការងារធ្វើ។ ហើយនៅពេលជនពិការមានការងារ ពួកគេអាចមានចំណូលដើម្បីទ្រទ្រង់ជីវភាពគ្រួសារក៏ដូចជាជួយសង្គមដែរ"។



មកដល់សព្វថ្ងៃនេះ មណ្ឌលបន្ទាយព្រាបគឺមានបណ្តុះបណ្តាលនូវ ៥ជំនាញ: ចម្លាក់ អេឡិចត្រូនិច ម៉ាស៊ីន កសិកម្ម និងកាត់ដេរ និងមានសិស្ស សរុបប្រមាណ ១១០នាក់ អាយុពី១៨ឆ្នាំ ទៅ៤០ឆ្នាំ។

លោកអ៊ូ អ៊ីនដុន ក៏បញ្ជាក់ថា: "ថាមពលនៃក្តីសង្ឃឹមនៃជនពិការជាអ្វីដែលយើងចង់បាន។ ហេតុនេះហើយទើបយើងយកចិត្តទុកដាក់ខាងគុណភាព ដើម្បីឱ្យពួកគេមានជំនាញពិតប្រាកដ ដែលអាចឱ្យគេ ក្រោកឈរតស៊ូក្នុងជីវិតបាន"។

ត្រង់ចំនុចនេះលោកឃ្លៀងវ៉ាន អះអាងថា មកដល់ពេល នេះ សាលាយើងបានក្លាយជាគំរូខាងការបណ្តុះបណ្តាលមានគុណភាព ដែលរដ្ឋាភិបាលបានទទួលស្គាល់ស្តង់ដាររបស់យើងផងដែរ។

February-2010.qxd 6/10/2010 2:47 PM Page 8

# ព័ត៌មានទូទៅ



Photos : DR

## កម្ពុជាកសាងឧបករណ៍ផលិតថាមពលអគ្គិសនីពីខ្យល់

ឧបករណ៍ផលិតអគ្គីសនីពីកម្លាំងខ្យល់មួយបានត្រូវដាក់សម្ពោធដោយរដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន និងលោកអគ្គរដ្ឋទូតបែលហ្សិក និងភារៈធារីសហភាពអឺរ៉ុបនៅប្រទេសកម្ពុជា ។

ឧបករណ៍នេះបានត្រូវគេដំឡើងនៅកំពង់ផែអន្តរជាតិខេត្តព្រះសីហនុ ក្រោមទឹកប្រាក់ជំនួយពីសហភាពអឺរ៉ុប ចំនួន ១,២លានអឺរ៉ូ និងថវិកាបដិភាគរបស់រដ្ឋាភិបាលកម្ពុជា កំពង់ផែអន្តរជាតិខេត្តព្រះសីហនុ និងរដ្ឋាភិបាលបែលហ្សិក ។

វាគឺជាគម្រោងសាកល្បងមួយក្នុងគោលបំណងប្រើប្រាស់ថាមពលកកើតឡើងវិញនៅកម្ពុជា ។

ក្រៅពីថាមពលខ្យល់ ថាមពលកកើតឡើងវិញដែលកម្ពុជាប្រើខ្លះក្នុងពេលនេះ មានដូចជា ជីវម៉ាស់ ដែលគេ ទាញចេញពីលាមកសត្វកម្ទេចកម្ទីកសិកម្ម និងពន្លឺព្រះអាទិត្យជាដើម ។

## ប្រមុខរដ្ឋាភិបាល : កម្ពុជាមានផ្ទៃដីគ្រប់គ្រាន់សម្រាប់ធានានិរន្តរភាពស្បៀងអាហារ

សម្ដេចហ៊ុន សែន ប្រមុខរដ្ឋាភិបាលកម្ពុជា បានមានប្រសាសន៍កាលពីថ្ងៃទី២០ ខែមករា កន្លងទៅថា កម្ពុជាមានផ្ទៃដីគ្រប់គ្រាន់សម្រាប់អភិវឌ្ឍន៍កសិឧស្សាហកម្ម និងផលិតស្បៀងអាហារចិញ្ចឹមប្រជាជន ។

សម្ដេចបានមានប្រសាសន៍នៅចំពោះមុខអ្នកសេដ្ឋកិច្ចក្នុងស្រុក និងអាស៊ីថា ស្បៀងអាហារជាបញ្ហាធំដោយសារបច្ចុប្បន្ននេះ អ្នកដាំដុះមួយចំនួនមិនមែនដាំដុះដើម្បីចិញ្ចឹមមនុស្សនោះទេ គឺគេដាំដុះ សម្រាប់ចិញ្ចឹមម៉ាស៊ីន ។ សម្ដេចបានព្រមានថា : "អ្នកដាំដុះត្រូវតែថ្លឹងថ្លែងឱ្យបានហ្មត់ចត់រវាងផ្ទៃដីដាំដុះសម្រាប់ចិញ្ចឹមក្រពះមនុស្ស និងផ្ទៃដីដាំដុះសម្រាប់ចិញ្ចឹមម៉ាស៊ីន តែសម្រាប់កម្ពុជា គឺអត់ទាន់ជួបប្រទះបញ្ហានេះនៅឡើយទេ " ។ សម្ដេចបានបន្តទៀតថា កម្ពុជាសព្វថ្ងៃនេះមិនទាន់បញ្ហាទេ ហើយកម្ពុជានៅសេសសល់សក្ដានុពលជាពិសេស គឺមានផ្ទៃដី យ៉ាងច្រើនដើម្បីផលិតស្បៀងអាហារសម្រាប់បំពេញតម្រូវការក្នុងស្រុកផង និងសម្រាប់ការនាំចេញទៀតផង ។

## ក្រុមហ៊ុនមកពីអូស្ត្រាលីចង់វិនិយោគ លើវិស័យកសិកម្ម ៦០០លានដុល្លារ

លោកភីតធើ គូស្ដេឡូ អតីតរដ្ឋមន្ត្រីហិរញ្ញវត្ថុអូស្ត្រាលីបានអះអាងថា ក្រុមហ៊ុនមួយមានគម្រោងនឹងធ្វើការវិនិយោគ នៅក្នុងប្រទេសកម្ពុជាលើវិស័យកសិកម្ម មានទំហំទឹកប្រាក់រហូតដល់ទៅ ៦០០លានដុល្លារ ។ គម្រោងវិនិយោគមហាសាលនេះបានត្រូវលើកឡើងនៅពេលដែលលោកភីតធើ ចូលជួបជាមួយនឹងឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទីស្ដីការគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី ២១ ខែមករា កន្លងទៅ ។

វិស័យកសិកម្មដែលក្រុមហ៊ុននេះចាប់អារម្មណ៍នោះ គឺរួមមានដំណាំស្រូវដំណាំចេក ដំណាំអំពៅ ដូងប្រេង និងចំការម៉ៃសាក់ ។

ដំណាំទាំងនេះគឺអាចទាមទារនូវដីវិនិយោគដែលមានទំហំប្រមាណជា ១០ម៉ឺនហិចតា ។

តាមការអះអាងរបស់មន្ត្រីកម្ពុជា ប្រសិនបើគម្រោងនេះដើរនោះ វានឹងអាចស្រូបយកកម្មករប្រមាណជា ១៥០០០នាក់ឱ្យចូលធ្វើការ ។

**ខាន់ ភីរម្យ**

## គ្រោះរញ្ជួយដីហៃទីសម្លាប់ជីវិតមនុស្ស ២០០០០០នាក់



គ្រោះរញ្ជួយដី ដែលបានកើតមានឡើងនៅប្រទេសហៃទី កាលពីថ្ងៃទី១២ ខែមករា កន្លងទៅនេះត្រូវបានគេធ្វើការប៉ាន់ប្រមាណថា វាបានសម្លាប់ជីវិតប្រជាជនប្រមាណរហូតដល់ ២០០០០០នាក់ ។

ក្រៅពីសម្លាប់ជីវិតមនុស្សហើយនោះ គេបានធ្វើការព្យាករណ៍ទៀតថា គ្រោះរញ្ជួយដីដ៏ធ្ងន់ធ្ងរនេះ បានធ្វើឱ្យរបួសមនុស្សចំនួនប្រមាណជា ២៥០០០០នាក់ ហើយធ្វើឱ្យប្រជាពលរដ្ឋហៃទីចំនួន ២លាននាក់ នៅក្នុងចំណោម ប្រជាពលរដ្ឋសរុបចំនួន ៩លាននាក់ គឺបាត់បង់ផ្ទះសម្បែង និងទីជម្រកផងដែរ ។

គ្រោះរញ្ជួយដីនេះ វាបានកើតមានឡើងនៅក្នុងរង្វាស់ ៧រិចទ័រ នៅចំនីងរដ្ឋធានីព័រអូប្រាង របស់ប្រទេសហៃទីនៅទ្វីបអាម៉េរិកមួយនេះ ។

នាបច្ចុប្បន្ននេះ ក្រុមសង្គ្រោះ និងក្រុមមនុស្សធម៌អន្តរជាតិជាច្រើនកំពុងតែត្រូវបានបញ្ជូនទៅកាន់ប្រទេសដ៏ក្រីក្រ មួយនេះនៅក្នុងគោលបំណងស្វែងរកជនរងគ្រោះ និងធ្វើជាកម្មវិធីជំនួយមនុស្សធម៌ផ្សេងៗដើម្បីសម្រាលទុក្ខវេទនារបស់ប្រជាជន ។

## ២០ឆ្នាំទៀតប្រទេសថ្មីជាច្រើននឹងក្លាយជាមហាអំណាចសេដ្ឋកិច្ច

នៅក្នុងឆ្នាំ២០៣០ខាងមុខនេះ គេបានព្យាករណ៍ថា ប្រទេសថ្មីៗជាច្រើនទៀតនឹងក្លាយទៅជាមហាអំណាចសេដ្ឋកិច្ចពិភព-លោក នៅក្នុងនោះ ក៏មានមានចិនផងដែរ ។

ក្រុមហ៊ុនប្រាយវាត់ធើហួស ឃូបភ័រ ជាក្រុមហ៊ុនផ្ដល់ប្រឹក្សាយោបល់អំពីធុរៈកិច្ចកំពូល ក៏បានអះអាងថា នៅក្នុងឆ្នាំ២០៣០ នៅក្នុងចំណោមប្រទេសមហាអំណាចសេដ្ឋកិច្ចធំៗ ទាំង១០ នៅលើពិភពលោក គឺមានចិនជាប្រទេស ទី១ បន្ទាប់មក គឺអាម៉េរិក ឥណ្ឌា ជប៉ុន ប្រេស៊ីល រុស្ស៊ី អាល្លឺម៉ង់ ម៉ិចស៊ិក បារាំង ហើយនិងប្រទេសអង់គ្លេស ។

ការព្យាករណ៍នេះ គឺផ្អែកទៅតាមកំណើនសេដ្ឋកិច្ច និងសន្ទុះនៃការអភិវឌ្ឍន៍របស់ប្រទេសទាំងអស់នៅលើពិភពលោក ។

នៅក្នុងចំណោមប្រទេសទាំងអស់នៅលើពិភពលោក អត្រាផលិតផលនៅក្នុងស្រុកសរុបរបស់ចិន និងឥណ្ឌា បានកើនឡើងយ៉ាងឆាប់រហ័សបើប្រៀបធៀបនឹងសហរដ្ឋអាម៉េរិក និងអឺរ៉ុប ។

មកដល់ពេលបច្ចុប្បន្ននេះ មហាអំណាចសេដ្ឋកិច្ចពិភពលោកទាំង១០ គឺមានអាម៉េរិក ជប៉ុន ចិន អាល្លឺម៉ង់ បារាំង អង់គ្លេស អ៊ីតាលី រុស្ស៊ី អេស្ប៉ាញ និងប្រេស៊ីល ។

# កិច្ចសម្ភាសន៍

## បវរកញ្ញាមីន : “បើកាយពិការទៅហើយ សូមកុំពិការចិត្ត”

**ខាន់ ភីរម្យ**

*ក្រោយសង្គ្រាមអស់រយៈពេល៣០ឆ្នាំ កម្ពុជាគឺជាប្រទេសសម្បូរមីនមួយនៅលើពិភពលោក ហើយក៏មានជនពិការច្រើនដោយសារតែគ្រាប់មីន។ ដើម្បីយល់អំពីការលំបាក និងការតស៊ូក្នុងជីវិតពិការ អ្នកនាំសារ សូមណែនាំមិត្តអ្នកអានឱ្យស្គាល់កញ្ញាដុះ សុភាព ជាបវរកញ្ញាមីន។*



Photo : DR

កញ្ញាដុះ សុភាព បវរកញ្ញាមីនឆ្នាំ២០០៩

**អ្នកនាំសារ: តើកញ្ញាមានអាយុប៉ុន្មាន? ហើយមូលហេតុអ្វីបានជាកញ្ញាពិការ?**

**កញ្ញាដុះ សុភាព:** ចាស់ ! ខ្ញុំមានអាយុ ១៩ឆ្នាំបច្ចុប្បន្ន ខ្ញុំគឺជាសិស្សវិទ្យាល័យសម្តេចឪ ក្នុងក្រុងបាត់ដំបង ។ ខ្ញុំអត់ចាំថា ខ្ញុំពិការដោយសារអ្វី? និងអាយុប៉ុន្មានដែរ? ។ ប៉ុន្តែម៉ាក់ខ្ញុំប្រាប់ថា ខ្ញុំធ្លាក់ខ្លួនពិការ តាំងពីអាយុ ៦ឆ្នាំ នៅពេល ដែលខ្ញុំទៅលេងឪពុកខ្ញុំដែលធ្វើជាទាហាននៅស្រុកបង្វិល ។

**អ្នកនាំសារ: តើមូលហេតុអ្វីបានជាកញ្ញាសម្រេចចិត្តដាក់ពាក្យចូលរួមក្នុងការប្រកួតបវរកញ្ញមីននៅកម្ពុជាកាលពីឆ្នាំ២០០៩ទៅនេះ?**

**កញ្ញាដុះ សុភាព:** ដំបូងខ្ញុំក៏ស្ទាក់ស្ទើរដែរក្នុងការបង្ហាញគេថា ខ្ញុំជាជនពិការមួយរូប តែក្រោយមកខ្ញុំសម្រេចចិត្តចូលរួមដើម្បីបង្ហាញអំពីភាពក្លាហានរបស់ខ្ញុំក្នុងនាមជាជនពិការមួយរូប ។

**អ្នកនាំសារ: តើកញ្ញាជួបការលំបាកយ៉ាងណាសម្រាប់ឆាកជីវិតជាជនពិការ ហើយតើធ្លាប់មានអារម្មណ៍តូចចិត្តនឹងខ្លួនឯងដែរឬទេ?**

**កញ្ញាដុះ សុភាព:** ខ្ញុំមិនចាំទេកាលពីនៅតូច ។ ប៉ុន្តែចាប់តាំងពីខ្ញុំដឹងក្តីពេលណាមក ខ្ញុំតែងតែមានអារម្មណ៍តូចចិត្តនឹងខ្លួនឯងជានិច្ច ។ រស់នៅជា ជនពិការមិនជារឿងដែលងាយស្រួលទេ ។ ដំបូងខ្ញុំត្រូវប្រឈមនឹងការបង្អាប់ពីមិត្តភក្តិ ហើយសូម្បីតែបងប្អូនបង្កើតក៏មានម្តងម្កាលដែរ ។ ប៉ុន្តែខ្ញុំយល់ថា បើយើងពិការទៅហើយ និងរវល់តែតូចចិត្តនោះ តើវាមានប្រយោជន៍អ្វី?

**អ្នកនាំសារ: តើសព្វថ្ងៃកញ្ញាមានមុខរបរធ្វើអ្វី? ហើយតើកញ្ញាអាចធ្វើអ្វីបាននៅក្នុងគ្រួសារ?**

**កញ្ញាដុះ សុភាព:** ខ្ញុំក៏ជាសិស្សថ្នាក់ទី១២ មួយរូប ហើយកំពុងតែត្រៀមខ្លួនប្រឡងដើម្បីសម្រេចគោលបំណងរបស់ខ្ញុំទៅថ្ងៃអនាគត ដែលចង់ធ្វើជាគណនេយ្យករ ឬក៏អ្នករដ្ឋបាលមួយរូបនឹងគេ ។ នៅក្នុងគ្រួសារ ថ្វីត្បិតតែខ្ញុំពិការ តែខ្ញុំនៅតែអាចជួយកិច្ចការគ្រួសារខ្លះៗដូចជា ដាំបាយ លាងចានជំនួសដៃជើងប៉ាម៉ាក់របស់ខ្ញុំបានខ្លះដែរ ។

**អ្នកនាំសារ: តើកញ្ញាចូលចិត្តរៀនមុខវិជ្ជាអ្វីនិងទទួលបានចំណាត់ថ្នាក់យ៉ាងណាដែរក្នុងសាលា?**

**កញ្ញាដុះ សុភាព:** ខ្ញុំចូលចិត្តរៀនមុខវិជ្ជាសីល-ធម៌ ប្រវត្តិវិទ្យា ភូមិវិទ្យា ហើយនិងអក្សរសាស្ត្រខ្មែរ ។ ក្នុងថ្នាក់ ខ្ញុំរៀនជាប់ចំណាត់ថ្នាក់លេខ១២ ។

**អ្នកនាំសារ: តើកញ្ញាមានចំណាប់អារម្មណ៍ចង់ផ្តាំផ្ញើអ្វីខ្លះទេទៅកាន់មិត្តភក្តិរបស់កញ្ញា ហើយក៏ដូចជាជនពិការទាំងឡាយនៅក្នុងប្រទេស?**

**កញ្ញាដុះ សុភាព:** ខ្ញុំមិនមានអ្វីសំខាន់ទេ តែអ្វីដែលខ្ញុំចង់ផ្តាំផ្ញើទៅមិត្តភក្តិរបស់ខ្ញុំនោះគឺថា សូមកុំមើលងាយជនពិការ ហើយត្រូវជួយលើកទឹកចិត្តជនពិការ ហើយក៏សូមប្រាប់ទៅជនពិការទាំងអស់ថា បើយើងពិការហើយ សូមកុំអស់សង្ឃឹមនៅក្នុងជីវិត ត្រូវមានការតស៊ូតទៅទៀត ហើយកុំស្តាប់ ឬខូចអារម្មណ៍ នៅពេលដែលគេបង្អាប់ ។ យើងត្រូវតែតស៊ូឡើងជានិច្ច ។ “បើយើងធ្លាក់ខ្លួនពិការរាង-កាយ ហើយ ក៏សូមកុំពិការចិត្តទៀត” ។



Photo : DR

កញ្ញាដុះ សុភាព បវរកញ្ញាមីន ថតរូបអនុស្សាវរីយ៍ជាមួយក្រុមគ្រួសារ។ នេះគឺជាសេចក្តីក្លាហានរបស់ជនពិការដែលហានប្រឈមមុខនឹងការពិតតាមរយៈការបញ្ចេញសមត្ថភាពនៅក្នុងសង្គម។

### បវរកញ្ញាមីននៅកម្ពុជា

កញ្ញាដុះ សុភាព បានជាប់ការជ្រើសរើសបវរកញ្ញាមីននៅក្នុងប្រទេសកម្ពុជា នាឆ្នាំ ២០០៩ កន្លងទៅនេះ។ កញ្ញាអះអាងថា: “ខ្ញុំសប្បាយចិត្តណាស់ដែលជាប់ការជ្រើសរើសនេះ ហើយក៏មិននឹកថា ខ្ញុំពិការហើយ នៅមានឱកាសបែបនេះទេ”។

កញ្ញាសុភាព គឺជាយុវសិស្សនៅវិទ្យាល័យសម្តេចឪក្រុងបាត់ដំបង ហើយជាកូនស្រីទី២ នៅក្នុងគ្រួសារដែលមានកូនប្រុស២ និងស្រី៣នាក់។ ឪពុកនាងគឺជាអតីតទាហាន ហើយម្តាយគឺជាមេផ្ទះ។ កញ្ញាគឺជាបេក្ខនារីមួយរូបនៅក្នុងចំណោមបេក្ខនារី ២០រូប ដែលបានចុះឈ្មោះប្រឡងបវរកញ្ញាមីនប្រចាំឆ្នាំ២០០៩ តាមរយៈរូបថតដោយអ្នកសិល្បៈជនជាតិន័រវេស្ស ឈ្មោះ ម៉រថេន ប្រាវិក។

## បទយកការណ៍

# ស្ថានភាពចរាចរណ៍ផ្លូវគោកនៅកម្ពុជាកំពុងតែ ប្រ

**ខាន់ ភីរម្យ**

មន្ត្រីសង្គមស៊ីវិល មន្ត្រីរដ្ឋាភិបាល ហើយប្រជាពលរដ្ឋ បានអះអាងថា ទោះបីជាស្ថានភាពអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកនៅកម្ពុជា នៅតែចោទជាបញ្ហា។ ប៉ុន្តែវាកំពុងតែមានស្ថានភាពប្រសើរឡើងជាបន្តបន្ទាប់ផងដែរ។

កញ្ញាសាន សុជាតា មន្ត្រីកម្មវិធីអប់រំសុវត្ថិភាពចរាចរណ៍នៃអង្គការជនពិការអន្តរជាតិ ក៏បានមានប្រសាសន៍ថា បើនិយាយអំពីទិដ្ឋភាពនៃការអនុវត្តច្បាប់ចរាចរណ៍ទាំងអស់របស់ប្រជាពលរដ្ឋខ្មែរ គឺហាក់ដូចជានៅមិនទាន់បានល្អទេ។ ប៉ុន្តែបើពិនិត្យទៅមើលស្ថានភាព ចរាចរណ៍ផ្លូវគោក ឆ្នាំ២០០៩ កន្លងទៅដោយធៀបនឹងឆ្នាំ២០០៨ និងជាពិសេសក្រោយពេល ដែលច្បាប់ចរាចរណ៍បានចូលជាធរមាននោះ កញ្ញាបានយល់ឃើញថាការគោរពច្បាប់ហាក់ដូច ជាមានស្ថានភាពល្អប្រសើរជាង បណ្តាឆ្នាំមុន។ កញ្ញាបានឱ្យដឹងថា: "ខ្ញុំមិនសំដៅទៅលើការអនុវត្តច្បាប់ចរាចរណ៍ទាំងអស់ទេ។ ប៉ុន្តែបើពិនិត្យលើការគោរពល្បឿន ការប្រើប្រាស់គ្រឿងស្រវឹង និងការពាក់មួកសុវត្ថិភាព ខ្ញុំយល់ថា នេះមានការគោរពគួរឱ្យកត់សម្គាល់។ រីឯអាជ្ញាធរមានសមត្ថកិច្ចក៏បានរឹតបន្តឹងករណីនេះបានប្រសើរផងដែរ"។ កញ្ញាបានបន្តទៀតថា: "ជាក់ស្តែង ករណីពាក់មួកសុវត្ថិភាពកាលពីឆ្នាំ២០០៨ អ្នកនៅទីក្រុងភ្នំពេញដែលបានពាក់មួកសុវត្ថិភាព គឺមានប្រមាណជា២៤ទៅ២៥%ទេ។ ប៉ុន្តែលុះមកដល់ខែកញ្ញាឆ្នាំ២០០៩កន្លងទៅនេះ យើងបានឃើញថាចំនួនប្រជាពលរដ្ឋដែលពាក់មួកសុវត្ថិភាព គឺបានកើនឡើង ប្រមាណជា ៨៥% ដែលវាបញ្ជាក់ថា នេះគឺជាសញ្ញាវិជ្ជមានមួយ។ កញ្ញាបានឱ្យដឹងទៀតផងដែរថា ពីមួយឆ្នាំទៅមួយឆ្នាំ ស្ថានភាពចរាចរណ៍នៅប្រទេសកម្ពុជាបន្តរីកចម្រើនជាលំដាប់ ហើយប្រជាពលរដ្ឋក៏កាន់តែមានការយល់ដឹងផងដែរ។

តាមការអះអាងរបស់កញ្ញាសុជាតា ការជំរុញឱ្យប្រជាពលរដ្ឋអនុវត្តច្បាប់ចរាចរណ៍ឱ្យបាន ១០០% វាមិនមែនអនុវត្តបានភ្លាមនោះទេ វាត្រូវការអប់រំពេលវេលា និងការអនុវត្តតាមជំហាន១។ កញ្ញាក៏បានឱ្យដឹងថា ជាក់ស្តែងឆ្នាំនេះ ដោយសារតែយើងពិនិត្យឃើញថា ៨០% នៃជនរងគ្រោះដល់ជីវិត គឺកើតមានឡើង ដោយសារតែពួកគាត់បើកបរម៉ូតូ ដោយមិនមានមួកសុវត្ថិភាព។ ដូច្នេះយើងបានព្យាយាមពិភាក្សាដើម្បីជំរុញ និងលើកកម្ពស់ឱ្យប្រជាពលរដ្ឋពាក់មួកសុវត្ថិភាព។ កញ្ញា បានឱ្យដឹងថា: "ស្រុកគេដែលស្ថានភាពចរាចរណ៍បានល្អប្រសើរនោះ មកពីគេអនុវត្ត និងមានច្បាប់យូរមកហើយ តែស្រុកយើងទើបតែមានច្បាប់ផ្លូវការថ្មីៗនេះតែប៉ុណ្ណោះ"។

ពាក់ព័ន្ធនឹងករណីអនុវត្តនូវច្បាប់ចរាចរណ៍នេះ លោកហ៊ុម យ៉ាន ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់នៃអគ្គនាយកដ្ឋាននគរបាលជាតិ បញ្ចេញយោបល់ប្រហាក់ប្រហែលគ្នានេះដែរ។ លោកក៏បានអះអាងថា នៅក្នុងឆ្នាំ២០១០នេះ អាជ្ញាធរមានសមត្ថកិច្ចនឹងបន្តពង្រឹងនូវច្បាប់ចរាចរណ៍នេះបន្តទៅទៀត។ លោកបានមានប្រសាសន៍ថា ក្រោយច្បាប់ចរាចរណ៍ បានចេញជាធរមានមកនាឆ្នាំ២០០៩ កន្លងទៅ



Photo : S. Philong

ម៉ាស៊ីនវ៉ាស់ជាតិអាកុល ពង្រឹងច្បាប់ចរាចរណ៍

### ប្រវត្តិច្បាប់ចរាចរណ៍ផ្លូវគោកកម្ពុជា

ច្បាប់ស្តីអំពីចរាចរណ៍ផ្លូវគោកនៅក្នុងប្រទេសកម្ពុជា គឺជាច្បាប់មួយដែលបានអនុម័តដោយរដ្ឋសភា កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៦ កន្លងទៅ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣។ ច្បាប់នេះបានត្រូវព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា យល់ស្របតាមទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទីពីរ នីតិកាលទី២ និងព្រះមហាក្សត្រព្រះអង្គឡាយព្រះហស្តលេខា កាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំដដែល។

ច្បាប់នេះមានទាំងអស់១២ជំពូក និង៩៥មាត្រា។ ច្បាប់នេះបានត្រូវបោះពុម្ព និងចែកចាយដោយគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក អង្គការជនពិការអន្តរជាតិបែលហ្ស៊ិក ក្រោមជំនួយឧបត្ថម្ភពីសហគមន៍អឺរ៉ុប ប្រជាជនជប៉ុន និងអង្គការសហប្រតិបត្តិការអន្តរជាតិ បែលហ្ស៊ិក។

# ងតែ ប្រសើរឡើង



នេះ យើងសម្រេចឱ្យយានយន្តដែលចរាចរណ៍ នៅក្នុងប្រទេសកម្ពុជា ប្រមាណ៩០% ឱ្យបំពាក់កញ្ចក់ និងមានផ្លាកលេខ សម្រាប់ទោចក្រយានយន្ត និងផ្លាកលេខសម្រាប់រថយន្ត ។ នាឆ្នាំ២០១០នេះយើងគ្រោងនឹងបន្តការងារលើការជំរុញ ឱ្យប្រជាពលរដ្ឋគោរពច្បាប់ចរាចរណ៍នេះបន្តទៀត ។

រហូតមកដល់ពេលនេះ បើទោះបីជាច្បាប់ចរាចរណ៍បានចេញក៏ដោយ ។ តែសកម្មភាពអនុវត្តនូវច្បាប់ចរាចរណ៍នៅក្នុងប្រទេសកម្ពុជា ហាក់ដូចជាទើបតែបានមួយភាគតូចតែប៉ុណ្ណោះ គឺមានជាអាទិ៍ការពាក់មួកសុវត្ថិភាព ដាក់កញ្ចក់ ដាក់ខ្សែក្រវ៉ាត់សម្រាប់រថយន្ត ការត្រួតពិនិត្យជាតិសុរា ការត្រួតពិនិត្យល្បឿននៅក្នុងការបើកបរ និងការដាក់ផ្លាកលេខជាដើម ។ តែទន្ទឹមនឹងនោះសកម្មភាពរំលោភច្បាប់ចរាចរណ៍ ក៏គេសង្កេតឃើញថានៅតែមានជាបន្តបន្ទាប់ ដូចជាករណីមិនគោរពនូវភ្លើងចរាចរណ៍ និងគំនូសច្បាប់ចរាចរណ៍ជាដើម ។

ប្រជាពលរដ្ឋមួយរូបដែលសុំមិនបញ្ចេញឈ្មោះបានឱ្យដឹងដែរថា សម្រាប់ច្បាប់ចរាចរណ៍នេះគាត់សង្កេតឃើញដែរថា អ្នកដែលគោរព នៅតែគោរព ហើយក៏ចេះតែគោរពទៅ ។ ប៉ុន្តែសម្រាប់អ្នកដែលមិនគោរពនៅតែមិនគោរព ។ គាត់បានបញ្ជាក់ថា : "ពេលខ្លះភ្លើងក្រហមទៅហើយ គាត់អត់ឈប់ទេ នៅតែទៅមុខរហូត ដល់ផ្លូវម្ខាងទៀត សម្រុកមកដែរ អត់កន្លែងចេញ ស្ទះទាំងអស់គ្នាជាញឹកញាប់ ។ ជួនកាលទៀតឃើញផ្លូវស្ទះគាត់អត់ចាំសន្សឹមៗទេ គាត់វ៉ាគេទៅចំណើផ្លូវម្ខាងទៀតក៏មាន" ។

ពាក់ព័ន្ធទៅនឹងផែនការនេះ លោកយ៉ានក៏មានប្រសាសន៍ថា នេះជាបញ្ហាដែលយើងនឹង កំពុងតែយកចិត្តទុកដាក់ ហើយគ្រោងចាត់វិធានការដែរ ។ មកដល់នឹងពេលនេះ យើងអត់ទាន់អនុវត្តភ្លាមទេ យើងកំពុងតែស្ថិតក្នុងដំណាក់កាលអប់រំនិងឱ្យគាត់ភ្ញាក់រលឹក ហើយយើងនឹងអនុវត្តវិធានការក្តៅនៅពេលក្រោយ ។ លោកបានរៀបរាប់ថា ឆ្នាំទៅយើងសម្រេចឱ្យយានយន្តមានស្លាកលេខ ហើយទោចក្រយានយន្តឱ្យដាក់កញ្ចក់ និងពាក់មួកសុវត្ថិភាព ហើយ ឆ្នាំ២០១០នេះ យើងគ្រោងនឹងបន្តការងារលើបញ្ហានៃបណ្ណបើកបរ បញ្ហាសុវត្ថិភាពដឹកជញ្ជូន និងការគ្រប់គ្រងលើបច្ចេកទេសរបស់យានយន្ត ។ លោកក៏បានបញ្ជាក់ថា : "ដោយសារតែដូច្នេះហើយបានជាយើងតម្រូវឱ្យអ្នកបើកបរទាំងអស់ ត្រូវតែមានបណ្ណបើកបរ ហើយទៅថ្ងៃមុខ បើអ្នកបើកបរបើកបរដោយមិនមានបណ្ណ ពួកគេអាចនឹងប្រឈមមុខចំពោះមុខច្បាប់យ៉ាងធ្ងន់ធ្ងរ" ។ លោកបានបន្តថា បើតាមច្បាប់អ្នកបើកបរ ដែលមិនមានបណ្ណ គឺអត់ពិន័យជាប្រាក់ទេ ត្រូវប្រឈមមុខនឹងការឃាត់ខ្លួននិងដាក់ពន្ធធនាគារ ពី៦ថ្ងៃទៅដល់១ខែ ហើយពិន័យជាប្រាក់ទៅតាមតុលាការវិនិច្ឆ័យទោស ។

លើពិភពលោក គ្រោះថ្នាក់ចរាចរណ៍គឺជាបញ្ហាមួយ ដែលគេសម្គាល់ឃើញថា មានការកើនឡើងជារៀងរាល់ឆ្នាំ ។ គេបានធ្វើការព្យាករណ៍ថា គ្រោះថ្នាក់ចរាចរណ៍ បានសម្លាប់មនុស្សប្រមាណជា ២៣ លាននាក់ ហើយ តំបន់ដែលគ្រោះថ្នាក់ជាងគេនោះ គឺនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដោយតួលេខបង្ហាញថា ប្រមាណជា ៨៥%នៃជនរងគ្រោះទាំងអស់រស់នៅ ពិសេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ។ នៅក្នុងតំបន់នោះដោយរួមទាំងប្រទេសកម្ពុជាផងនោះ គេបានប៉ាន់ប្រមាណដែរថា មានជនរងគ្រោះរហូតដល់ទៅ ៤៤% ។

នៅប្រទេសកម្ពុជា មូលហេតុសំខាន់នៃគ្រោះថ្នាក់នេះ ក៏ត្រូវបានគេស្តីបន្ទោសទៅលើកំណើននៃយានយន្ត និងការមិនគោរពច្បាប់ចរាចរណ៍ ដោយរួមទាំងបញ្ហានៃការបើកបរ ដោយបរិភោគគ្រឿងស្រវឹងដែរ ។ ហើយបច្ចុប្បន្ននេះ ជនរងគ្រោះដែលបានបាត់បង់ ដោយសារគ្រោះថ្នាក់ចរាចរណ៍ មានស្ថានភាពប្រហាក់ប្រហែលនឹងជនរងគ្រោះដោយសារតែជំងឺអេដស៍ផងដែរ ។

កញ្ញាសុជាតាបានអះអាងដែរថា រហូតមកដល់ពេលនេះ ជនរងគ្រោះដល់ជីវិតដោយសារតែគ្រោះថ្នាក់ចរាចរណ៍នៅកម្ពុជា ជាបញ្ហាចោទ ។ សម្រាប់របាយការណ៍ឆ្នាំ២០០៩ កន្លងទៅថ្មីៗនេះ អង្គការ HIB នៅមិនទាន់ដឹងច្បាស់នៅឡើយទេដោយសារតែតួលេខ ដែលបានមកពីការសិក្សា គឺនៅមិនទាន់បានបញ្ចប់នៅឡើយទេ ។

ប៉ុន្តែបើយោងតាមរបាយការណ៍ប្រព័ន្ធព័ត៌មានជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក នៅកម្ពុជា ប្រចាំឆ្នាំ២០០៨ បានឱ្យដឹងថា នៅក្នុងរយៈពេលបីឆ្នាំកន្លងទៅ ចំនួនគ្រោះថ្នាក់ចរាចរណ៍ មានការកើនឡើងគួរឱ្យកត់សម្គាល់ ។ តួលេខក៏បង្ហាញថា នៅក្នុងឆ្នាំ២០០៦ ចំនួនប្រជាពលរដ្ឋដែលបាត់បង់ជីវិតដោយសារតែគ្រោះថ្នាក់ចរាចរណ៍ គឺមានចំនួន ១២៩២នាក់ ក្នុងឆ្នាំ២០០៧ គឺបានកើនឡើងដល់ ១៥៤៥នាក់ ហើយនៅក្នុងឆ្នាំ២០០៨ គឺបានកើនដល់ចំនួន ១៦៣៨នាក់ ។

## មូលហេតុនៃគ្រោះថ្នាក់ចរាចរណ៍នៅកម្ពុជា

ប្រភពចម្បងនៃគ្រោះថ្នាក់ចរាចរណ៍នៅក្នុងប្រទេសកម្ពុជា គឺដោយសារកត្តាពីរចម្បង គឺការបើកបរល្បឿនលឿន និងការប្រើប្រាស់គ្រឿងស្រវឹងហួសកំណត់ក្នុងពេលបើកបរ។

របាយការណ៍ប្រព័ន្ធព័ត៌មានជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនៅកម្ពុជា ប្រចាំឆ្នាំ២០០៨ បានឱ្យដឹងថា ៤៧%នៃគ្រោះថ្នាក់ចរាចរណ៍បង្កឡើងដោយការបើកបរល្បឿនលឿន និង១៤%ផ្សេងទៀត ដោយការសេពគ្រឿងស្រវឹង។ ហើយបើនិយាយអំពីជនរងគ្រោះដល់ជីវិតវិញ ៥១% គឺដោយសារការបើកបរក្នុងល្បឿនលឿន និង១៨%ផ្សេងទៀតបង្កឡើងដោយការសេពគ្រឿងស្រវឹង។ ប្រភពដដែលនោះបានឱ្យដឹងទៀតថា ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក បានកើនឡើងស្ទើរតែទ្វេដង ក្នុងរយៈពេល៥ឆ្នាំ ចុងក្រោយនេះ។ នៅក្នុងឆ្នាំ២០០៨ គេរកឃើញថា ក្នុងមួយថ្ងៃមានអ្នកបាត់បង់ជីវិតដោយសារតែគ្រោះថ្នាក់ចរាចរណ៍ប្រមាណ ៤.៥នាក់។

February-2010.qxd 6/10/2010 2:47 PM Page 12



# អបអរសាទរការរំឭកខួបព្រះសហគមន៍កាតូលិកបាត់ដំបង

**អារុណា**



Photo : Phiruna

នាថ្ងៃទី៥ ខែមករា ២០១០ នៅព្រះសហគមន៍កាតូលិកបាត់ដំបង មានប្រារព្ធកម្មវិធី បុណ្យរំលឹកខួប២២០ឆ្នាំ នៃការកកើតព្រះសហគមន៍កាតូលិកនៅភូមិភាគបាត់ដំបងនេះ ។

ចាប់តាំងពីការកកើតរហូតដល់សព្វថ្ងៃ បងប្អូនគ្រីស្តបរិស័ទបានខិតខំតស៊ូដើម្បីធ្វើឱ្យព្រះសហគមន៍មានការរីកចម្រើនដ៏គួរឱ្យកត់សម្គាល់ ក្នុងនោះមានការស្ថាបនានូវមណ្ឌលសកម្មភាពជាច្រើន ដូចជា មណ្ឌលព្យាបាលអ្នកជំងឺ មណ្ឌលស្វាគមន៍ជនពិការដោយសារគ្រាប់មីននិងដោយប៉ូលីយ៉ូ មណ្ឌលវប្បធម៌តម្បាញ កាត់ដេរ និងសកម្មភាព ជាច្រើនទៀតសម្រាប់រួមចំណែកក្នុងការកសាងព្រះសហគមន៍ ក៏ដូចជាសង្គមជាតិដែរ ។

មានប្រសាសន៍ក្នុងកម្មវិធីនោះដែរ លោកអភិបាលគីកេ អះអាងថា : "ខ្ញុំមានសេចក្តីរីករាយខ្លាំងណាស់ដោយនៅថ្ងៃនេះ យើងទាំងអស់គ្នា បានមកទីនេះជាព្រះសហគមន៍កណ្តាលរបស់ព្រះសហគមន៍ភូមិភាគបាត់ដំបង ។យើងជាមហាគ្រួសាររបស់ព្រះជាម្ចាស់ដើម្បីអបអរនូវពិធីរំឭកខួប ២២០ឆ្នាំ ដែលព្រះសហគមន៍ បានចាប់កំណើតនៅលើទឹក ដីខេត្តបាត់ដំបងនេះ" ។ លោកមានប្រសាសន៍បន្ថែមទៀតថា : "ខ្ញុំមានសេចក្តីកោតសសើរ ខ្លាំងណាស់ចំពោះ កិច្ចខិតខំប្រឹងប្រែងរបស់គ្រីស្តបរិស័ទ ក្នុងការតស៊ូកសាងព្រះសហគមន៍ឱ្យចម្រើនលូតលាស់ និងបានបន្តដល់យើងជាគ្រីស្តបរិស័ទជំនាន់ក្រោយ ។ ដូច្នេះគប្បីយើងទាំងអស់គ្នាត្រូវរួមសាមគ្គីគ្នាដើម្បីកសាងព្រះសហគមន៍ ដូចដូនតាពីជំនាន់ដើម ដែលបានកសាងតាំងពីដៃទទេរហូតដល់រុងរឿងដូចសព្វថ្ងៃនេះ ។ នេះជាអ្វីដែលអស្ចារ្យ ដែលព្រះជាម្ចាស់បាន សម្តែងមកលើប្រជាជនកម្ពុជាយើង ឱ្យក្លាយជាបុត្រធីតារបស់ព្រះអង្គ" ។

កញ្ញាវណ្ណី មកពីព្រះសហគមន៍ខ្នាចរមាស បាននិយាយថា : "នាងខ្ញុំមាននូវសេចក្តីរីករាយណាស់សម្រាប់ការរំឭកខួប២២០ឆ្នាំ របស់ព្រះសហគមន៍កាតូលិកបាត់ដំបង ។ ចំពោះខ្ញុំជាអ្នកជំនាន់ក្រោយរបស់ព្រះសហគមន៍កាតូលិកខ្នាចរមាស យើងមានលោកបូជាចារ្យប្រចាំការ និងជួយណែនាំ ។ ដូច្នេះយើងទាំងអស់គ្នា មានភាពកក់ក្តៅ និងមានអំណរសប្បាយក្នុងការកសាងព្រះសហគមន៍" ។

សូមបញ្ជាក់ដែរថា កម្មវិធីនេះមានការអញ្ជើញចូលរួមអបអរសាទរអំពីសំណាក់បងប្អូនប្រមាណជាង ៥០០នាក់ ដែលមកពីព្រះសហគមន៍ភូមិភាគបាត់ដំបង ចំណោម ខ្នាចរមាស តាពូង តាអំ និគមប៉ៃលិន កំពង់ឆ្នាំង តាហែន ស្វាយស៊ីសូផុន ឆ្នុកទ្រូស្ទឹង ជាមួយបណ្តាមណ្ឌលជាច្រើនដែលជាបណ្តាញរបស់ព្រះសហគមន៍កាតូលិកជាច្រើនផងដែរ ។

ក្នុងកម្មវិធីនេះ គ្រីស្តបរិស័ទក៏បានរួមគ្នាសម្តែងរបាំកោតសរសើរដល់ព្រះម្ចាស់ ។ គ្រីស្តបរិស័ទសូមថ្វាយអ្វីដែលជាការីកចម្រើនទៅព្រះជាម្ចាស់ និងក៏សូមអង្វរដល់ព្រះអង្គប្រទាន និងជួយពង្រឹងចំពោះការងារនៃអ្នកប្រកាសដំណឹងល្អ ។ អំណរសប្បាយលើព្រះជាម្ចាស់ជាកម្លាំងព្រះសហគមន៍កាតូលិក ។

## ពិធីសំណាក់ធម៌សម្រាប់ត្រៀមទទួលពិធីត្រាស់ហៅ

ព្រះសហគមន៍កាតូលិកសៀមរាបនៃភូមិភាគបាត់ដំបង បានរៀបចំធ្វើនូវពិធីសំណាក់ធម៌រយៈពេល ៣ថ្ងៃ សម្រាប់ក្រុមស្តាប់ព្រះគម្ពីរលាន់ឮឡើងចំនួន ៦៨នាក់ ដែលពិធីនេះគឺណែនាំដោយលោកបូជាចារ្យ ទម្លាប់សុផល ព្រមទាំងគ្រូអប់រំជំនឿនៃព្រះសហគមន៍នេះកាលពីថ្ងៃទី២៥-២៧ ខែមករាកន្លងទៅ ។

លោកធឹម ធន់ ជាអ្នកសម្របសម្រួលគ្រូអប់រំជំនឿនៅព្រះសហគមន៍កាតូលិកសៀមរាបបានមានប្រសាសន៍ឱ្យដឹងថា : "សម្រាប់ពិធីសំណាក់ធម៌ដែលបានធ្វើឡើងលើកនេះ យើងមានគោលបំណងចង់ឱ្យបងប្អូនទាំងអស់ស្គាល់អំពីអំណោយទាន នៃសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ ដែលនាំឱ្យយើងចេះចែករំលែកសម្រាប់អ្នកដទៃទៀត និងឱ្យយល់កាន់តែច្បាស់ពីរបៀបរស់នៅក្នុងព្រះសហគមន៍កាតូលិក ដោយផ្ញើជីវិតទាំងស្រុងទៅលើព្រះយេស៊ូ និងបោះបង់ចោលរាល់អបិយជំនឿផ្សេងៗ ដែលពួកគាត់ធ្លាប់មានពីមុនមក" ។

នាឱកាសនោះដែរលោកធឹម ធន់ បានសំណូមពរទៅដល់គ្រីស្តបរិស័ទឱ្យជួយលើកទឹកចិត្តដល់គ្នា បង្ហាញពីការយកចិត្តទុកដាក់និងសាកសួរសុខទុក្ខ ដើម្បីឱ្យក្រុមនេះ មានភាពកក់ក្តៅ និងមានកម្លាំងក្នុងការដើរតាមព្រះយេស៊ូ ។

ក្រុមស្តាប់ព្រះគម្ពីរលាន់ឮឡើងនឹងទទួលនូវពិធីត្រាស់ហៅ (ជំហានទី២) នៅថ្ងៃទី២១ កុម្ភៈ ខាងមុខនេះមុននឹងទទួលនូវអគ្គសញ្ញាជ្រមុជទឹកនៅព្រះសហគមន៍កាតូលិកសៀមរាប ។

**បក្សីក្រហម**

February-2010.qxd 6/10/2010 2:47 PM Page 13



# សិក្ខាសាលានៅមណ្ឌលសកម្មភាពភ្នំពេញ

មណ្ឌលសកម្មភាពភ្នំពេញ បានរៀបចំនូវសិក្ខាសិលាមួយ ដែលមានការចូលរួម ពីព្រះសហគមន៍ចំនួន៦ រួមមាន សែនសុខ តួតាំង កោះនរា ពោធិ៍ធំ ក្តិកណ្តាលនិងផ្សារតូច។ យុវជនប្រមាណ ៣៤នាក់ បានចូលរួមពិភាក្សា អំពីប្រធានបទ : "តើខ្ញុំទទួលសញ្ញាអ្វីខ្លះពីព្រះជាម្ចាស់ក្នុងជីវិតប្រចាំថ្ងៃ?"។

សិក្ខាសាលានេះទទួលការសម្របសម្រួលពីបងប្រុសសុផល និងតឿ អ្នកណែនាំកម្មវិធីយុវជន នៅមណ្ឌលសកម្មភាពភ្នំពេញ។ សិក្ខាសាលានេះ បានធ្វើឡើងពីរថ្ងៃ គឺទី២-៣ ខែមករា ឆ្នាំ២០១០។

នៅក្នុងសិក្ខាសាលានោះដែរ គេផ្តោតលើចំណុចសំខាន់មួយចំនួន: ការមើលវីឌីអូអ្នកម្តាយតេរ៉េសា និងការអធិដ្ឋានបែបតាំងសមាធិដោយរិះគិតអំពីអតីតកាលដើម្បីឱ្យយុវជនកាន់តែមានជំនឿរឹងមាំ និងយល់កាន់តែច្បាស់អំពីសេចក្តីស្រឡាញ់។

កញ្ញាវីន សុខា អ្នកចូលរួមសិក្ខាសាលានេះមានយោបល់ថា : "ខ្ញុំពិតជាមានចិត្តរន្ធត់នៅពេលដែលបានមើលនិងស្វែងយល់អំពីរឿងអ្នកម្តាយតេរ៉េសា ដោយសារតែ ការលះបង់សេចក្តីស្រឡាញ់ និងការចែករំលែកនូវអ្វីៗដែលគាត់មានទៅអ្នកក្រីក្រ"។

សូមបញ្ជាក់ផងដែរថា សិក្ខាសាលានេះនឹងរៀបចំធ្វើឡើងម្តងទៀត នៅថ្ងៃទី២៨-២៩ ខែកុម្ភៈ ឆ្នាំ ២០១០ នៅមណ្ឌលសម្មភាពភ្នំពេញដដែលក្រោមប្រធានបទដែលបានគ្រោងទុកសម្រាប់អប់រំខាងផ្លូវវិញ្ញាណដល់យុវជនឱ្យបានល្អប្រសើរ។

**ចិត្រា**



ក្រុមយុវជននៅព្រះសហគមន៍សន្ត យ៉ូសែបជួបជុំគ្នា ថតរូបជាអនុស្សាវរីយ៍ បន្ទាប់ពីពួកគេបានចែករំលែកបទពិសោធន៍ក្នុងអង្គសិក្ខាសាលា

Photo : Tra

## CCF រៀបចំតាំងពិព័រណ៍ គំនូរឯកវាទនៃអ្នកតថ្លង់



Photo : S. Philong

ស្នាដៃសិល្បៈ ចំនួន ១០០ផ្ទាំង របស់អ្នកសិល្បៈករខ្មែរជាអាណិកជនអាមេរិកមួយរូប បានត្រូវមជ្ឈមណ្ឌលវប្បធម៌បារាំង CCF បានសម្រេច យកមកតាំងពិព័រណ៍ ជូនសាធារណៈជនទូទៅចូលទស្សនាកំសាន្ត។

ពិព័រណ៍នោះ នឹងបើកចំហជូនសាធារណៈជនចូលទស្សនា ចាប់ពីថ្ងៃទី២៨ មករា រហូតដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១០។

លោក ឆាត ភាសាត ជាវិចិត្រករបានមានប្រសាសន៍ថា ផ្ទាំងគំនូរទាំងនេះ បានត្រូវដាក់តាំងនៅក្រោមប្រធានបទឯកវាទនៃអ្នកតថ្លង់ដើម្បីឆ្លុះបញ្ចាំងអំពីទិដ្ឋភាពរបស់មនុស្សដែលមានភាពស្ងៀមស្ងាត់ ពេលដែលពួកគាត់រស់នៅកាលពីសម័យប៉ុលពត។

**ខាន់ ភីរម្យ**

# បុណ្យព្រះយេស៊ូប្រសូតនៅព្រះវិហារសន្តយ៉ូសែប

**ចិត្រា**

បុណ្យព្រះយេស៊ូប្រសូត ឬបុណ្យណូអែលនោះ តែងត្រូវប្រារព្ធនៅថ្ងៃទី២៤-២៥ ខែធ្នូ។ សម្រាប់ព្រះវិហារសន្តយ៉ូសែប(ផ្សារតូច) ក៏បានប្រារព្ធពិធីបុណ្យដ៏អធិកអធមនេះផងដែរ។

គ្រីស្តបរិស័ទម្នាក់និយាយថា ពិធីបុណ្យនេះបានទទួលជោគជ័យ ដោយសារមានការរៀបចំ កម្មវិធីពីសមាជិកគណៈកម្មាធិការក្នុងព្រះសហគមន៍ ក្នុងនោះក្រុមយុវជន ជាកម្លាំងស្វាហាប់ ជួយរុញច្រានឱ្យកម្មវិធីរឹតតែមានភាពអធិកអធម។

លោកហ៊ិន វ័ត្ថតារ៉ា ដែលជាប្រធានក្រុមយុវជន បានមានប្រសាសន៍ថា : "អ្វីៗដែលយើងធ្វើនេះមិនមែនធ្វើសម្រាប់ខ្លួនឯងផ្ទាល់ ឬសម្រាប់បុគ្គលណាម្នាក់ទេ គឺយើងធ្វើសម្រាប់អបអរដល់ថ្ងៃដែលព្រះយេស៊ូបានប្រសូត និងចង់ឱ្យគ្រីស្តបរិស័ទ បានទទួលនូវភាពរីករាយនៅថ្ងៃបុណ្យនេះ"។

រីឯលោកហែម ស៊ីងឡុង ដែលជាសមាជិកក្រុមយុវជនក៏មានយោបល់ផងដែរថា : "ថ្វីត្បិតតែរូបកាយហត់មែនពិត។ តែអ្វីដែលសំខាន់នោះ គឺភាពសប្បាយរីករាយដែលចេញអំពីស្នាមញញឹមរបស់គ្រីស្តបរិស័ទក្នុងពេលចូលរួម និងសេចក្តីស្រលាញ់ពីព្រះជាម្ចាស់"។

ជាមួយគ្នានេះដែរ នៅពាក់កណ្តាលអាធ្រាតថ្ងៃទី២៤ វេលាម៉ោង ១២យប់ ក្រុមយុវជនទាំងអស់បានធ្វើការអធិដ្ឋាននៅខាងមុខខ្ទមរបស់ព្រះយេស៊ូ ដើម្បីពង្រឹងជំនឿ និងសេចក្តីស្រលាញ់ឱ្យមានកាន់តែរឹងមាំឡើង ហើយក៏ដើម្បីធ្វើការដឹងគុណចំពោះសេចក្តីស្រលាញ់ដែលមកពីព្រះជាម្ចាស់ ដែលព្រះអង្គបានប្រទានមកដល់មនុស្សលោក។



Photo : Tra

លក់វត្ថុអនុស្សាវរីយ៍នៅថ្ងៃបុណ្យព្រះយេស៊ូប្រសូត

# សកម្មភាពនានានៃព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា

## ព្រះសហគមន៍កាតូលិក

*សកម្មភាពនៅថ្ងៃបុណ្យព្រះយេស៊ូប្រសូត ។ ដំណើរទស្សនកិច្ចរបស់កាឌីណាល់ ចូសេហ្វ ហ្សេន មកពីហុងកុង ។ អធិដ្ឋានតេហ្សេនៅបឹងទំពុន ។*



កញ្ញាបុស្បា ប៉ាន់ សម្ដែងទេពកោសល្យនៅសាលាដុនបូស្កូ



ប្រកួតបង្ហោះខ្លែងនៅព្រះសហគមន៍ចំការទៀងកាលពីថ្ងៃ២៤ ធ្នូ ឆ្នាំ២០០៩ ដើម្បីអបអរសាទរបុណ្យព្រះយេស៊ូប្រសូត



និស្សិតទេវវិទ្យាល័យប្រគល់វត្ថុអនុស្សាវរីយ៍ដល់លោកកាឌីណាល់ចូសេហ្វ ហ្សេន ពេលលោកមកកម្ពុជាកាលដើមខែមករា



ការអធិដ្ឋានតេហ្សេរំឭកឆ្នាំបូជាចារ្យ នៅព្រះសហគមន៍កាតូលិកបឹងទំពុន ទីក្រុងភ្នំពេញ កាលពីថ្ងៃទី៤ ខែមករា



ការសម្ដែងល្ខោនស្បែកអំពីដំណើរជីវិតរបស់ព្រះយេស៊ូនៅថ្ងៃទី២៤ ធ្នូ ឆ្នាំ២០០៩ នៅព្រះសហគមន៍ចំការទៀង



រៀងរាល់ឆ្នាំ ព្រះសហគមន៍កាតូលិកចំការទៀង នៅស្រុកត្រាំកក់ ខេត្តតាកែវ ដឹកនាំដោយលោកអភិបាល អូលីវីយេ តែងរៀបចំសិល្បៈដ៏ធំដើម្បីអបអរសាទរបុណ្យព្រះយេស៊ូប្រសូត

February-2010.qxd 6/10/2010 2:48 PM Page 15

## បទយកការណ៍ព្រះសហគមន៍កាតូលិក

# វិស្សមកាលដែលមានប្រយោជន៍របស់យុវជនបារាំង

ហ៊ូ សុខធារី

សំឡេងដំធ្វើផ្ទះប៉ូកប៉ាក់ៗ និងសំឡេងចម្រៀងយ៉ាងសប្បាយរីករាយជាភាសាបារាំង បានជំរុញឱ្យអ្នកភូមិរកាកណ្ដាល ខេត្តក្រចេះ ភ្ញាក់ផ្អើល គ្រប់ៗគ្នា រត់មកមើលក្រុមយុវជនបារាំង ចំនួន ១២នាក់កំពុងសប្បាយជាមួយការលីសសរឈើធ្វើផ្ទះ។

ម៉ាថាយ យុវជនបារាំង អាយុ៣២ឆ្នាំ ធ្វើជាអ្នកសម្របសម្រួលក្រុមបាននិយាយថា: "បងប្អូនភាគច្រើនដែលមកជាមួយយើងនៅពេលនេះ គឺសុទ្ធតែមានការងារធ្វើ នៅស្រុកបារាំង។ ប៉ុន្តែពួកគាត់ចង់ចំណាយពេលវេលាវិស្សមកាលឱ្យមានប្រយោជន៍សម្រាប់បងប្អូនខ្មែរ។ គោលបំណងសំខាន់គឺយើងផ្ដោតលើការបម្រើនិងមេត្តាករុណា។ គេក៏តែងថា បើយើងច្រើន យើងនឹងទទួលបានច្រើនដូចគ្នា។

ការជួយសង់ផ្ទះរបស់យុវជនស្ម័គ្រចិត្តបារាំងនេះត្រូវបានធ្វើឡើងនៅអំឡុងពាក់កណ្ដាលខែ១២ ឆ្នាំ២០០៩ រហូតដល់ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១០។

កញ្ញាអាន គ្រីស្ដែល ដឺ សារ៉ុញ៉ាក់ អាយុ៣២ឆ្នាំ ជនជាតិបារាំង និងជាវិស្វករបានប្រាប់ថា: "ខ្ញុំគិតថា វិស្សមកាលរបស់ខ្ញុំនាលើកនេះ ពិតជាសំណាងណាស់ព្រោះខ្ញុំអាចផ្ដល់នូវបរិយាកាសមួយ ដែលខ្ញុំមិនដែលធ្លាប់ធ្វើ។ សម្រាប់ខ្ញុំ ផ្ទះមានសារសំខាន់ជាងសាលា និងមន្ទីរពេទ្យ ព្រោះវាជាមូលដ្ឋានគ្រឹះក្នុងការចាប់ផ្ដើមជីវិតមនុស្ស។ ហើយនេះជាលើកទីមួយដែលខ្ញុំធ្វើដំណើរមកទ្វីបអាស៊ី ដែលធ្វើឱ្យខ្ញុំមានការប៉ះពាល់ផ្លូវចិត្តខ្លាំង ដោយសារបងប្អូននៅទីនេះក្រីក្រ ហើយរស់នៅក្នុងផ្ទះពុកបាក់បែក។

លោកសោម សុវណ្ណារ៉ា ដែលជាម្ចាស់ផ្ទះ មានមុខរបរជាកូនកាំបិតចុងភៅម្ហូបការ និងជាមេផ្ទះមានកូន ៣នាក់ បានប្រាប់ថា: "ខ្ញុំអរ និងសប្បាយចិត្តខ្លាំងណាស់។ ពីមុនខ្ញុំគិតថា សន្សំលុយធ្វើផ្ទះ។ ប៉ុន្តែពេលនេះមានផ្ទះ។ វាជួយខ្ញុំច្រើន។ ខ្ញុំមិនសូវខ្វល់ និងមានឱកាសសន្សំលុយសម្រាប់កូនរៀន"។

យុវនារីម៉ារី អេកូសា អាយុ២៨ឆ្នាំ មានមុខងារជាគ្រូពេទ្យផ្នែកពោះវៀន និងថ្លើម នៅឯប្រទេសបារាំង និងដែកាន់ញូញូរ បាននិយាយថា: "ដោយពុំធ្វើដំណើរកំសាន្តទៅកាន់ប្រទេសទំនើប នេះដូចជាកាតព្វកិច្ចមួយរបស់ខ្ញុំ។ ហើយវាក៏ជាការល្អមួយដែលយើងមានឱកាសធ្វើការជាក្រុមក្នុងគម្រោងតែមួយ។ ខ្ញុំមានអារម្មណ៍ល្អពីព្រោះជីវិតរបស់បងប្អូននៅទីនេះខុសពីយើងទាំងស្រុង។ ខ្ញុំមើលគេដូចជា អត់មានអ្វីទាំងអស់ ប៉ុន្តែគេសប្បាយរហូត។

ការកសាងផ្ទះនេះមានចំនួន២ខ្នង។ មួយខ្នង គឺធ្វើនៅឯភូមិក្ដុលលើ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម និងមួយខ្នងទៀតនៅខេត្តក្រចេះ។

លោកបូជាចារ្យអ៊ីវ៉ាន់បានបន្តថា: "ការសង់ផ្ទះដែលមានទំហំ ៤ គុណ៦ម នេះ ចំណាយថវិកាជាង ១៧០០ ដុល្លារ ដែលវាជាការឧបត្ថមមកពីអង្គការគូប ដឺ ពុស អុយម៉ានីទែរ៍។ សម្រាប់ខ្ញុំ ខ្ញុំពិតជារំភើប។ពួកគេគឺជាគំរូសម្រាប់យុវជនកម្ពុជា។ ពួកគេចំណាយទាំងថវិកា និងកម្លាំងពិសេសគឺចំណាយពេលវិស្សមកាលរបស់គេ ដើម្បីកសាងផ្ទះដល់បងប្អូនក្រីក្រ។ នេះជាសញ្ញាមួយ ដែលជួយឱ្យយុវជនខ្មែរចេះរិះគិតបន្ថែម ដើម្បីជួយដល់សហគមន៍នៅក្នុងភូមិនៅពេលអនាគត"។

តាមការឱ្យដឹងរបស់លោកម៉ាថាយ ថា អង្គការគូ ដឺ ពុស អុយម៉ានីទែរ៍ នឹងមានគម្រោងមកសង់ផ្ទះជូន ប្រជាជនម្ដងទៀតនៅខេត្តក្រចេះនេះ នៅពាក់កណ្ដាលខែកុម្ភៈនេះ។



Photo : H. Sokhteary

February-2010.qxd 6/10/2010 2:48 PM Page 16

# ព្រះសហគមន៍កាតូលិក

## "ព្រះសហគមន៍កាតូលិកគោរពសិទ្ធិ និងជំនឿអ្នកដទៃ"

**ខាន់ ភីរម្យ**



Photo : DR

លោកអន់តូនីសាមី ស៊ូសៃរាជ អភិបាលនៃព្រះសហគមន៍ភូមិភាគកំពង់ចាម មានប្រសាសន៍ថា : "ការប្រកាន់យកជំនឿ និងសិទ្ធិសេរីភាពខាងជំនឿ គឺជាជំហដែលព្រះសហគមន៍កាតូលិកតែងគោរពប្រណិប័តន៍ និងយកចិត្តទុកដាក់ខ្ពស់"។

លោកអភិបាល បានមានប្រសាសន៍បញ្ជាក់ថា: "ជំហររបស់ព្រះសហគមន៍ គឺយើងអត់មានការរិះគន់ដល់អ្នកដទៃឡើយ។ យើងមានការគោរព និងឱ្យតម្លៃព្រមទាំងយកចិត្តទុកដាក់យ៉ាងពិសេសទៅលើអ្នកដែលមានជំនឿ និងសាសនាផ្សេងៗ។ដូច្នេះរាល់ការប្រកាសដំណឹងល្អ ដែលចេញពីព្រះសហគមន៍កាតូលិក យើងក៏ប្រកាន់យកត្រឹមការបង្ហាញសេចក្ដីស្រលាញ់ដល់អ្នកដទៃតែប៉ុណ្ណោះ"។

លោកអន់តូនី សាមី មានប្រសាសន៍ថា របៀបបង្ហាញខ្លួន និងទិសដៅនៃព្រះសហគមន៍កាតូលិក មិនមែនធ្វើតាមរយៈការរិះគន់អ្នកដ៏ទៃនោះទេ។ ចំណុចនេះខាងក្រសួងធម្មការ និងកិច្ចការសាសនា លោកក៏បានដឹងដែរ។ ហើយលោកក៏តែងតែរំលឹកយើងជារឿយៗជាប្រចាំដែរដើម្បីឱ្យយើងចេះរស់នៅជាមួយគ្នាដោយសេចក្ដីសុខ ជាពិសេសនៅក្នុងកិច្ចប្រជុំអន្តរសាសនាដែលយើងមានអ្នកតំណាងទៅចូលរួមជាប្រចាំ។

លោកបន្តទៀតថា គោលដៅព្រះសហគមន៍ គឺបង្ហាញអំពីសេចក្ដីស្រលាញ់តាមរយៈការប្រកាសដំណឹងល្អ។ តែព្រះសហគមន៍កាតូលិកអត់ប្រកាន់យកការរិះគន់ចំពោះអ្នកដទៃឡើយ។ មធ្យោបាយដែលព្រះសហគមន៍កាតូលិកប្រើប្រាស់នៅក្នុងការប្រកាសដំណឹងល្អនោះគឺជាការប្រើប្រាស់ជីវិតផ្ទាល់ខ្លួនធ្វើជាសក្ខីភាព និងបង្ហាញពីគំរូល្អដល់អ្នកដទៃ ហើយបើនរណាចាប់អារម្មណ៍ហើយឆ្ងល់អំពីព្រះសហគមន៍កាតូលិក យើងអាចនឹង ប្រើប្រាស់នូវវិធីមួយទៀតគឺពាក្យសំដីដើម្បីឱ្យគេស្គាល់ពីយើង តែយើងក៏ប្រកាន់នូវជំហរឱ្យតម្លៃ និងគោរពសាសនាដទៃទៀតផងដែរ។

លោក ក៏បានបន្តឱ្យដឹងទៀតថា ព្រះសហគមន៍កាតូលិក គឺតែងមានទំនាក់ទំនងល្អជាមួយនិងគ្រប់សាសនាទាំងអស់នៅក្នុងប្រទេស ជាពិសេសគឺព្រះពុទ្ធសាសនាដែលជាសាសនារដ្ឋ។

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលរដ្ឋធម្មនុញ្ញបានចែងយ៉ាងច្បាស់ថា ព្រះពុទ្ធសាសនា គឺជាសាសនារបស់រដ្ឋ។ តែទោះបីជាយ៉ាងណាក៏ដោយរដ្ឋធម្មនុញ្ញក៏បានអះអាងអំពីការធានានូវសេរីភាពខាងជំនឿសាសនារបស់ប្រជាពលរដ្ឋផងដែរ។ ក្នុងនោះមានប្រជាពលរដ្ឋប្រមាណជាជាង ៩0% គឺជាអ្នកកាន់ព្រះពុទ្ធសាសនា ក្រៅពីនោះក៏មានកាន់នូវសាសនាផ្សេងៗ ដែរ ដូចជាឥស្លាមសាសនា គ្រីស្ត-សាសនា និងជំនឿលើកម្លាំងអភិធម្មជាតិជាដើម។

## ប្រតិទិនអភិបូជា

- **ភាសាខ្មែរ** : ព្រះវិហារសន្តយ៉ូសែបភ្នំពេញ (០១២ ៧៨២ ២៤១) ថ្ងៃច័ន្ទ-សៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក និងម៉ោង៤រសៀល។
  -កំពង់សោម (០១៦ ៨៤០ ៥៤០) ថ្ងៃច័ន្ទ ថ្ងៃពុធ និងថ្ងៃសុក្រ : ល្ងាចម៉ោង៥។ ថ្ងៃអង្គារ ថ្ងៃព្រហស្បតិ៍ និងថ្ងៃសៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក។
  -សៀមរាប (០៦៣ ៩៦៥ ២៨០) ថ្ងៃអាទិត្យ : ម៉ោង៧:៣០ព្រឹក។ ថ្ងៃច័ន្ទ-ថ្ងៃព្រហស្បតិ៍ : ព្រឹក ៦:៣០ម៉ោង។ ថ្ងៃសុក្រ : ម៉ោង ៦:៣០ល្ងាច។
  -បាត់ដំបង (ពេទ្យយាយជី) ថ្ងៃអាទិត្យ : ម៉ោង ៨:០០ព្រឹក។ ថ្ងៃច័ន្ទ : ល្ងាច៦:០០។ ថ្ងៃអង្គារ-សុក្រ : ម៉ោង៦:១៥ ព្រឹក។
- **Français** : 1er et 3ème Samedi du mois à 5:30pm ; 2ème et 4ème Dimanche du mois à 11:00am; à l'église de St. Joseph, #1788B, RN5, PP.
- **English** : - Phnom Penh : Sunday at 10: 00 am; at St. Joseph Church (#1788B, NR5, PP); Saturday at 5: 00 pm, at World Vision Cambodia (#2 St 71, PP); - Sihaknouk Ville : Sunday at 5:00 pm; # Catholic Church St.12 13 Mattapheap; H/P: 016 840 540 (Fr. Werachai); - Siem Reap : Saturday at 6:30 pm; #Catholic Church, No 027 East River Side Street. - Battambang : Saturday: at 6:00 pm at Battamabang Church (Pet Yeaychi), Rumchek 1, Rattanak, H/P: 012 911 147 (Fr. Totet).

February-2010.qxd 6/10/2010 2:48 PM Page 17




Photo : DR

# កំណាយស្ថានីយបុរាណ រកឃើញវត្ថុ នៅសម័យថ្មបំបែក និងថ្មរំលីង

**ខាន់ ភីរម្យ**

មន្ត្រីជាន់ខ្ពស់ប្រចាំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានអះអាងថា បើតាមរយៈកំណាយដែលបានធ្វើនៅស្ថានីយបុរាណវត្ថុវិទ្យានៅល្អាងស្ពាន ខេត្តបាត់ដំបង គេបានរកឃើញវត្ថុមានតម្លៃជាច្រើនរបស់បុព្វបុរសខ្មែរនាសម័យបុរាណ។

លោកហេងសុផាឌី ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានបេតិកភណ្ឌអះអាងដែរថា: "នៅទីនោះយើងរកឃើញវត្ថុខ្លះមានអាយុតាំងពី ៧000ឆ្នាំមុន គ្រិស្តរាជ រហូតដល់ឆ្នាំ៨២០ ជាសម័យអង្គរ ដែលជាសម័យរុងរឿងបំផុតនៅក្នុងប្រវត្តិសាស្ត្រខ្មែរ"។

បើតាមការអះអាងរបស់លោកសុផាឌី វត្ថុដែលគេរកឃើញនៅស្ថានីយល្អាងស្ពាននេះ គឺរួមមានឆ្អឹងសត្វ កុលាលភាជន៍ ឆ្អឹងមនុស្ស ឧបករណ៍ធ្វើអំពីថ្ម សំបកខ្យងខ្ចៅ និងឧបករណ៍ប្រើប្រាស់មួយចំនួនទៀត។ ខ្លះធ្វើអំពីថ្មបំបែក និងថ្មរំលីង ដែលគេរកឃើញវត្ថុទាំងអស់នេះ នៅក្នុងខែ១០ និង ១១ ឆ្នាំ២00៩នេះ។

ឆ្លងតាមភស្តុតាងពីការធ្វើកំណាយរួមគ្នា រវាងក្រុមអ្នកស្រាវជ្រាវខ្មែរ និងបារាំង រូងភ្នំដែលគេហៅថា ល្អាងស្ពាននេះ វាគឺជាកន្លែងរស់នៅរបស់បុព្វបុរសខ្មែរ ដែលមានអាយុកាលចំណាស់ជាងគេនៅក្នុងចំណោមទីកន្លែងនានាដោយរួមទាំងស្ថានីយបុរាណវត្ថុវិទ្យាផ្សេងៗទៀតផងដែរ។

លោកសុផាឌី ក៏បានអះអាងថា ក្រសួង ក្រុមអ្នកស្រាវជ្រាវកម្ពុជានិងបារាំងបន្តធ្វើការសិក្សាស្រាវជ្រាវនៅស្ថានីយល្អាងស្ពាននេះបន្តទៅមុខ រយៈពេល៤ឆ្នាំទៀត។ ឆ្នាំ ២០១០នេះ យើងក៏នឹងបន្តធ្វើកំណាយឱ្យបានជម្រៅចុះក្រោម ១ម ទៀត ហើយនិងបន្តរហូតដល់ជម្រៅប្រមាណ៤ម"។ លោកបន្តទៀតថា កម្រាស់ ១ម ចុះក្រោមនោះ ក្រុមអ្នកស្រាវជ្រាវរំពឹងដែរថា នឹងអាចរកឃើញនូវផ្នូរបុរាណរបស់បុព្វបុរសខ្មែរ និងវត្ថុមានតម្លៃខាងប្រវត្តិសាស្ត្រជាច្រើនដែរ ដើម្បីធ្វើជាភស្តុតាងសម្រាប់អះអាងប្រាប់ដល់ពិភពលោកថា ខ្មែរជាពូជសាសន៍ម្ចាស់ស្រុកដ៏ពិតប្រាកដមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ លោកបានបញ្ជាក់ថា: "វត្ថុតាងយើងរកឃើញសព្វថ្ងៃ ធ្វើឱ្យយើងអាចធ្វើការសន្និដ្ឋានបានដែរថា ជនជាតិខ្មែរ ជាជនជាតិចំណាស់មួយនៅទ្វីបអាស៊ី។ប៉ុន្តែយើងចង់ធ្វើការសិក្សាស្រាវជ្រាវ ដើម្បីស្វែងរកបានភស្តុតាងលំអិតជាងនេះទៅទៀត"។

## ណែនាំ

### រឿងអ្នកផ្សងព្រេងអារាត់អារាយ



សារិទ្ធ អាយុ២៥ឆ្នាំ មានសញ្ញាបត្រច្បាប់ពីរសន្លឹក មានប្រាក់ចាយគ្រប់គ្រាន់ មានរូបសម្បត្តិដ៏គួរសម និងមានសង្សារកំណាន់ចិត្ត...។ តែគេមានរោគធុញទ្រាន់នឹងជីវិត។ គេដាក់ទោសខ្លួនឯង និងសម្រេចចិត្តរស់ដូចមនុស្សបាតសង្គម ឬដើរអារាត់អារាយគ្រប់តំបន់ រួចយកស្ត្រីៗ ជាលេសដើម្បីធ្វើបាបខ្លួនឯង...

គេគិតថា ការទៅផ្សងព្រេងនៅប៉ារីស និងអឺរ៉ុប អាចជួយកែរោគចិត្តគេ និងអាចជួយ រកឧត្តមគតិឱ្យខ្លួនវិញ។ តែផ្ទុយទៅវិញ ជីវិតគេកាន់តែដុនដាបទៅៗ : ប្រាក់កាន់តែខើច អាកាសធាតុរឹតតែពិបាកទ្រាំ និងភាពឯកោ នៅចំកណ្តាលពិភពថ្មីដែលគ្មាននរណាខ្វល់ខ្វាយ។មិនចុះសម្រុងនឹងជីវិតនៅតែមិនចុះសម្រុងនឹងជីវិត។

លុះដល់ពេលគេជួបនាងបាបារ៉ា វេជ្ជបណ្ឌិតចិត្តសាស្ត្រ អគ្គលេខាធិការនៃវិទ្យាស្ថានអន្តរជាតិខាងឯកសារ និងជានារីមហាបញ្ញវន្តវ័យក្មេង ជីវិតសារិទ្ធមានការប្រែប្រួល។ ប្រែប្រួលទៅខាងល្អ ឬអាក្រក់?...

រឿងនេះនិពន្ធដោយលោក សុទ្ធ ប៉ូលីន។

### រឿងកូនកញ្ជ្រោងនៅកោះជ្រូនប់



នៅរដូវផ្ការីក លើកោះជ្រូនប់នៃប្រទេសជប៉ុន កូនកញ្ជ្រោងពីរក៏បានចាប់កំណើត។ កូនឈ្មោល វារពឹស ឆ្លល់ច្រើន និងពូកែចាប់សត្វដូចឪពុក។ ចំណែកកូនញីពូកែរំអួយ និងចូលចិត្តលេង ជាមួយមេអំបៅ។ ពួកគេធំធាត់ និងក៏រៀនរស់នៅតាមបែបធម្មជាតិយ៉ាងសុខសាន្ត។ តែជាអកុសលសង្គ្រាមឆាបឆេះឡើងក្តៅគគុក។ នៅលើកោះដ៏ស្ងប់ស្ងាត់ ស្រាប់តែលេចវត្តមានទាហានយ៉ាងសន្ធឹកសន្ធាប់។ ពួកគេត្រូវការស្បែកកញ្ជ្រោងយកមកដណ្តប់ដើម្បីទប់ទល់ភាពត្រជាក់។

ច្រើនឆ្នាំកន្លងផុតទៅ សង្គ្រាមក៏ចប់ដែរ។ នៅលើកោះមានផ្កាម៉ោងដប់សរីកស្គុះស្គាយដូចកំរាលព្រំ។ នៅកន្លែងមួយ គេឃើញមានផ្ការីកច្រើនជាងគេ ហើយផ្តុំគ្នាមានរាងដូចមេ ហើយនិងកូនកញ្ជ្រោង កំពុងដេកខ្សៀន។ នៅក្បែរនោះ គេក៏ឃើញអង្គប់ច្រែះចាប់មួយដែរ...

រឿងនេះស្ថិតនៅក្នុងកម្រងអក្សរសិល្ប៍ដ៏ល្បីល្បាញរបស់ជប៉ុន ដែលបកស្រាយពីតម្លៃជីវិតមនុស្ស-សត្វ និងបញ្ចូលសញ្ញាណសន្តិភាពក្នុងសន្តានចិត្តមនុស្សគ្រប់រូប។

**ហួត សុជាតា**

## ប្រវត្តិសាស្ត្រ

# សូម៉ាលី រដ្ឋរីករបណ្តាលឱ្យមានចោរសមុទ្រ

**ជាត សំភី**



### ភូមិសាស្ត្រ និងអំពីចោរសមុទ្រ

សូម៉ាលីមានផ្ទៃដី ៦៣៧ ៦៥៧ គម² និងមានប្រជាជនចំនួន ៩ ៥៥៨ ៦៦៦ នាក់ (ឆ្នាំ២០០៨) និងរាជធានី ម៉ូហ្គាឌីស្យូ។ ចោរសមុទ្រសូម៉ាលីកើតឡើងដោយកត្តាមួយចំនួនដូចជា : កង្វះខាតអំណាចរបស់រដ្ឋាភិបាលកណ្តាលក្នុងការបង្ក្រាប គឺជាកត្តាអនុគ្រោះដល់ដល់ការកើនឡើងនូវចោរសមុទ្រនៅតាមឆ្នេរសូម៉ាលី។ តាមហេតុផលសេដ្ឋកិច្ច ចោរសមុទ្រនៅសូម៉ាលីកើតឡើងពីព្រោះភាពក្រីក្ររបស់ប្រជាជនដែលបណ្តាលមកពីសង្គ្រាម ការកេងប្រវ័ញ្ច និងគ្រោះទុរភិក្ស។ តាមហេតុផលភូមិសាស្ត្រ ចោរសមុទ្រសូម៉ាលីទទួលផលប្រយោជន៍ពីផ្លូវពាណិជ្ជកម្មសមុទ្រដែលងាយចូលដល់។ ចំនុចទីបួន នេះជាទង្វើមួយដែលកំណត់ដោយប្រពៃណីរបស់ប្រទេស។

នេះគឺជារដ្ឋក្រីក្រនៅគែមខាងកើតទ្វីបអាហ្វ្រិក ដែលមានឆ្នេរជាប់នឹងមហាសមុទ្រឥណ្ឌា។ តាំងពីយូរយង់ណាស់មកហើយនេះ គឺជាតំបន់ ដែលត្រូវបានគ្រប់គ្រងដោយប្រជាជនជាចរកជន និងជាអ្នកគង្វាលចិញ្ចឹមសត្វដែលមានរូបភាពឆ្លាក់គូរនៅលើផ្ទាំងថ្មបុរាណ។

ពីសតវត្សរ៍ទី៩ ដល់សតវត្សរ៍ទី១២ អ្នកជំនួញជនជាតិមូស្លីមចូលមកដល់។ ប្រជាជនសូម៉ាលីបានចូលកាន់សាសនាឥស្លាមជាស្ថាពរនាសតវត្សទី១៣ គឺជាការចាប់ផ្តើម នៃព្រះរាជាណាចក្រ ដែលមានព្រះមហាក្សត្រគ្រប់គ្រងក្នុងងារជាស៊ុលតង់។ នៅអំឡុងមជ្ឈិមសម័យទីក្រុងមូស្លីមជាច្រើនមានការរីកចម្រើន។ ទំនាក់ទំនងជាមួយព្រះរាជាណាចក្រជិតខាងអេត្យូពី ដែលកាន់សាសនាគ្រិស្ត មានភាពតានតឹងជាខ្លាំងរហូតដល់ផ្ទុះសង្គ្រាមជាមួយគ្នា។

លុះមក មុនសង្គ្រាមលោកលើកទីពីរ ប្រទេសសូម៉ាលីត្រូវចែកជាពីរ។ ភាគជើងជាអាណានិគមអង់គ្លេស ហៅថា សូម៉ាលីឡេន និងភាគត្បូង គឺជាអាណានិគមអ៊ីតាលី ហៅថាសូម៉ាលីយ៉ា។

លុះចប់សង្គ្រាមលោកលើកទីពីរ នៅឆ្នាំ១៩៤៩ អង្គការសហប្រជាជាតិបានព្រមឱ្យប្រទេសអ៊ីតាលីធ្វើអាណាព្យាបាលលើសូម៉ាលីរយៈ ពេល ១០ឆ្នាំ។




Photos : DR

នៅឆ្នាំ១៩៦០ ប្រទេសសូម៉ាលីបានទទួល បានឯករាជ្យ រដ្ឋសូម៉ាលីបានកើតមានឡើងដោយការរលាយចូលគ្នារវាងសូម៉ាលីឡេនអាណានិគមរបស់អង់គ្លេស នៅភាគខាងជើង និងសូម៉ាលីយ៉ា របស់អ៊ីតាលីនៅភាគខាងត្បូង។

ពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៦៩ នៅក្រោមរដ្ឋការរបស់ប្រធានាធិបតី អាដេន អូស្មាន និងប្រធានាធិបតី អាដ ឡៀវ៉ាស៊ើត អាលី ប្រទេសសូម៉ាលី បានព្យាយាមស្ថាបនារដ្ឋាភិបាលប្រជាធិបតេយ្យ។ តែ ១ការប្រយុទ្ធនៅបន្តរវាងភាគខាងជើង និងភាគខាងត្បូង និងទំនាក់ទំនងយ៉ាងតានតឹង ជាមួយប្រទេសជិតខាងបានបង្កឱ្យមានអស្ថិរភាពជាច្រើនឆ្នាំ។

នៅឆ្នាំ១៩៦៩ ដដែល ប្រជាធិបតេយ្យបានដួលរលំ ឧត្តមសេនីយ៍ស៊ីយ៉ាដ បារ៍ បានដណ្តើមអំណាចតាមរយៈរដ្ឋប្រហារ។ ដោយមានទំនាក់ទំនងដ៏ជិតស្និត ជាមួយសហភាពសូវៀត បារ៍ បានប្រកាសថាសូម៉ាលី គឺជារដ្ឋសង្គម និយម។

ប្រទេសសូម៉ាលី ត្រូវបានធ្វើឱ្យរំដើបរំជួល នៅទសវត្សរ៍១៩៩០។ ក្រុមមន្ត្រីប្រកាន់បក្សពួក និងអំពើពុករលួយ បានធ្វើឱ្យខូចទំនុកចិត្តរបស់ប្រជាជនចំពោះរដ្ឋបាលមជ្ឈិម។ បរិយាកាសពុំសប្បាយចិត្តចេះតែកើនឡើងចំពោះរបបប្រធានាធិបតីផ្តាច់ការ ស៊ីយ៉ាដ បារ៍ ដែលនាំឱ្យដល់ការដួលរលំរបស់របបលោក នៅឆ្នាំ១៩៩១។ បន្ទាប់ពីនេះ សូម៉ាលីបានធ្លាក់ចូលក្នុងភាពជារដ្ឋអនាធិបតេយ្យ។ ស្តេចត្រាញ់នៃសង្គ្រាមទាំងឡាយក៏បានបន្តប្រយុទ្ធគ្នាដោយគ្មានមនោគមវិជ្ជាច្បាស់លាស់។ ស្តេចត្រាញ់សង្គ្រាម តែងប្រឆាំងការបង្កើតរដ្ឋាភិបាលកណ្តាលពីព្រោះវាអាចគំរាមកំហែងចំពោះសកម្មភាពខុសច្បាប់ពួកគេ ដូចជាការជួញគ្រឿងញៀនជាដើម។

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ



អ្នកនាំសារខែកុម្ភៈ ២០១០-
ដោយលោកគ្រូដួង សាខឡុ

**ថ្ងៃអាទិត្យទី៥ ក្នុងរដូវធម្មតា (ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១០)**

*លូកា ៥,១-១១*

សាវ័កដើមដំបូងរបស់ព្រះយេស៊ូ សុទ្ធតែជាអ្នកនេសាទ ។ លោកសិលាសុខចិត្តធ្វើតាមព្រះបន្ទូលព្រះយេស៊ូ ពេលនោះស្រាប់តែកិច្ចការរបស់គាត់ក៏កើតផលយ៉ាងច្រើនហួសពីការស្មាន ។

លោកសិលាជាគ្រីស្តទូតដើមដំបូងដែលទទួលមុខងារថែរក្សាកូនចៀមក្នុងនាមព្រះគ្រីស្ត ។ ក្នុងអត្ថបទនេះ ទូករបស់គាត់ចេញទៅនេសាទគឺជានិមិត្តរូបអំពីព្រះសហគមន៍ដែលចេញទៅប្រកាសដំណឹងល្អគ្រប់ទីកន្លែងក្នុងពិភពលោករហូតដល់សព្វថ្ងៃ ។ នៅថ្មីៗនេះសម្តេចប៉ាបបានតែងតាំងលោកអភិបាលថ្មីឱ្យថែរក្សាហ្វូងចៀមរបស់ព្រះគ្រីស្ត និងប្រកាសដំណឹងល្អតទៅទៀតនៅប្រទេសកម្ពុជា ដោយបន្តពីលោកអភិបាលជាទីស្រឡាញ់របស់យើងដែលចូលនិវត្តន៍ ។ លោកអភិបាលគ្រប់ៗជំនាន់សុទ្ធតែបន្តមុខងារពីលោកសិលាមក ។ តើខ្ញុំមានអំណោយទានណាដើម្បីរួមជាមួយលោកអភិបាលថ្មីក្នុងការប្រកាសដំណឹងល្អ?

**ថ្ងៃអាទិត្យទី៦ ក្នុងរដូវធម្មតា (ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១០)**

*លូកា ៦.១៧,២០-២៦*

មនុស្សគ្រប់ៗរូបតែងតែស្វែងរកសុភមង្គល ហើយមនុស្សភាគច្រើនស្វែងរកសុភមង្គលដោយពឹងលើអំណាច កិត្តិយស ឬទ្រព្យសម្បត្តិមាសប្រាក់ ។ល ។

ព្រះគ្រីស្តយាងមកប្រទានសុភមង្គលដ៏ពិតប្រាកដ ដល់មនុស្សយើង ដោយនាំយើងឱ្យផ្ចង់ចិត្តឆ្ពោះទៅកាន់ព្រះបិតាដែលស្រឡាញ់យើង ។ ព្រះអង្គមានព្រះបន្ទូលលើកទឹកចិត្តដែរថា អ្នកក្រខ្សត់ ស្រេកឃ្លាន... គ្មានអ្វីជាទីពឹងក្រៅពីព្រះជាម្ចាស់ នោះមានសុភមង្គលហើយ ។ ឯអ្នកដែលទទួលសុភមង្គលដោយពឹងលើសម្ភារៈលោកីយ៍នោះនឹងត្រូវវេទនាវិញ ព្រោះសម្បត្តិលោកីយ៍សម្រាប់តែលោកីយ៍នេះប៉ុណ្ណោះ មិនអាចនាំយើងឱ្យទៅកាន់ព្រះបិតាឡើយ ។ យើងជាគ្រីស្តបរិស័ទ ទោះត្រូវការទ្រព្យសម្បត្តិ ដូចអ្នកឯទៀតៗក្តី ក៏យើងមិនភ្លេចពីគោលដៅរបស់ខ្លួនដែរ ។ យើងខិតខំរកទ្រព្យសម្បត្តិ តែយើងគួរចាត់ចែងទ្រព្យសម្បត្តិនោះដើម្បីជាប្រយោជន៍ខ្លួនផង អ្នកឯទៀតៗផង និងសង្គមផង ។ តើទិសដៅនៃជីវិតខ្ញុំជាអ្វី?

**អាទិត្យទី១ ក្នុងរដូវអប់រំពិសេស (ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១០)**

*លូកា ៤,១-១៣*

ក្នុងចិត្តមនុស្សយើងមានលោភៈ ទោសៈ មោហៈ តាំងពីកំណើតមក ដែលយើងហៅថាមារ ។ នៅវាលរហោឋានក្នុងនាមប្រជារាស្ត្រព្រះជាម្ចាស់ និងជាតំណាងមនុស្សទាំងអស់ ព្រះយេស៊ូឈ្នះការល្បួងពីមារគ្រប់យ៉ាង ដែលមារនាំមនុស្សយើងឱ្យឃ្លាតឆ្ងាយពីព្រះបិតា ។ មារល្បួងឱ្យព្រះអង្គប្រើអំណាចពីព្រះបិតាដើម្បីអាហារ និងដើម្បីបានទ្រព្យសម្បត្តិ បានអំណាច និងបានការកោតសរសើរ ។ តែព្រះអង្គរំឭកទៅមារថា មនុស្សមិនមែនរស់ដោយសារតែអាហារប៉ុណ្ណោះទេ ។ មនុស្សត្រូវតែថ្វាយបង្គំព្រះជាម្ចាស់ ហើយផ្ញើជីវិតលើព្រះអង្គ មនុស្សក៏មិនត្រូវល្បងលនឹងព្រះជាម្ចាស់ដែរ ។ ព្រះយេស៊ូជ្រើសរើសយកព្រះបិតាក្នុងគ្រប់កាលៈទេសៈទាំងអស់ ។ ក្នុងរដូវអប់រំពិសេស គឺជាឱកាសដែលគ្រីស្តបរិស័ទត្រូវតម្រង់ចិត្តគំនិតទៅរកព្រះបិតាវិញ ដោយសូមអង្វរព្រះយេស៊ូប្រទានកម្លាំងមកខ្លួនផង ។ តើសព្វថ្ងៃមារល្បួងខ្ញុំយ៉ាងណា ?

**អាទិត្យទី២ ក្នុងរដូវអប់រំពិសេស (ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១០)** *លូកា ៩,២៨ខ-៣៦*

ព្រះយេស៊ូធ្វើដំណើរជាមួយពួកសាវ័ក ។ ព្រះអង្គតែងតែរកឱកាសពន្យល់ពួកគេដោយប្រុងប្រយ័ត្នអំពីឋានៈរបស់ព្រះអង្គ គឺព្រះគ្រីស្តត្រូវរងទុក្ខលំបាក រហូតសោយទិវង្គតមុនពេលព្រះអង្គទទួលសិរីរុងរឿង ។ ពួកសាវ័កពិបាកទទួលសេចក្តីនេះណាស់ ព្រោះគេយល់ពីឋានៈព្រះគ្រីស្តតាមរបៀបលោកីយ៍ ។ បន្ទាប់មកព្រះអង្គសម្តែងសិរីរុងរឿងឱ្យគេឃើញដើម្បីលើកទឹកចិត្តគេ និងពង្រឹងជំនឿគេផង ។

ព្រឹត្តិការណ៍នេះក៏ជាពន្លឺសម្រាប់ពង្រឹងជំនឿដល់យើងសព្វថ្ងៃដែរ គឺបើពេលយើងរងទុក្ខលំបាកដោយប្រការណាមួយដូចជាធ្លាក់ខ្លួនឈឺ ជួបគ្រោះថ្នាក់ ការបែកបាក់ ការបោះបង់ ការប្រមាថពីអ្នកដទៃ ឬការខកចិត្ត-ល- ក៏ឱ្យយើងនឹកឃើញថា ខ្លួនក៏បានរួមជាមួយព្រះគ្រីស្តដែលរងទុក្ខលំបាករហូតសោយទិវង្គតដែរ ។ ហើយក៏សង្ឃឹមថា ខ្លួននឹងរួមជាមួយព្រះគ្រីស្តដែលទទួលព្រះជន្មថ្មីដ៏រុងរឿងនោះវិញដែរ ។ តើខ្ញុំផ្ញើជីវិតទាំងស្រុងលើព្រះគ្រីស្តដែលទទួលព្រះជន្មថ្មីដ៏រុងរឿងយ៉ាងណា?

**ព័ត៌មាន**

## អំពើហិង្សាប្រឆាំងនឹងគ្រីស្តសាសនានៅឥណ្ឌា

បើតាមសេចក្តីរាយការណ៍សារព័ត៌មាន Zenit កាលពីថ្ងៃទី២៧ ខែមករានេះ បានឱ្យដឹងថា ព្រះសហគមន៍កាតូលិកចំនួនបីកន្លែងផ្សេងៗគ្នា បានទទួលរងការវាយប្រហារនៅក្នុងប្រទេសឥណ្ឌាដោយក្រុមអ្នកជាតិនិយមសាសនាហិ៊ុនដូ ក្នុងនោះ រួមមានការបំផ្លាញព្រះឈើឆ្កាង ព្រះយេស៊ូគ្រីស្ត ក្នុងព្រះវិហារឡូឌីស នៃភូមិភាគការ៉ា ការបំផ្លាញលើព្រះវិហារសន្តអន់តូនីឡូឌីស គ្រូតូ ហើយនិងការបំផ្លាញនូវរូបសំណាកព្រះនាងម៉ារីទាំងស្រុង ចំពោះព្រះវិហារក្រុមគ្រួសារដ៏វិសុទ្ធនៅក្នុងភូមិភាគមីស័រ ។

ព្រឹត្តិការណ៍នេះកើតឡើងបន្ទាប់ពីប្រព័ន្ធផ្សព្វផ្សាយមួយ បាននិយាយពីការរើសអើងការប្រកាន់ជាតិសាសន៍ប្រឆាំងនឹងនិស្សិតឥណ្ឌាដែលជាក្រុមនិស្សិតបរទេសធំលំដាប់ទីពីរ បន្ទាប់ពីក្រុមនិស្សិតជនជាតិចិន ដែលកំពុងសិក្សាក្នុងប្រទេសអូស្ត្រាលី ។

ទីភ្នាក់ងារព័ត៌មានរបស់ក្រុមបេសកកម្មបរទេសមកពីប្រទេសបារាំង បាននិយាយថា ការវាយប្រហារអស់ទាំងនេះត្រូវបានមើលឃើញថា ជាការតបរបស់ក្រុម ជាតិនិយមសាសនាហិ៊ុនឌូ ដែលបានទាមទារឱ្យរដ្ឋាភិបាលខ្លួនចាត់វិធានការតបតនឹងរដ្ឋាភិបាលអូស្ត្រាលីដែលមិនទប់ស្កាត់ហិង្សាដែលកើតចំពោះនិស្សិតឥណ្ឌាក្នុងប្រទេសអូស្ត្រាលី ។

សូមបញ្ជាក់ថាគ្រីស្តបរិស័ទឥណ្ឌានៅក្នុងប្រទេសបន្តស្ថិតនៅក្រោមរលកនៃការវាយប្រហារចាប់តាំងពីឆ្នាំ២០០៨ ដែលបានចាប់ផ្តើមដំបូងនៅក្នុងភូមិភាគអូរីសា ។




Photo : DR

Zenit

## “ជៀសពីគ្រឿងញៀន ដើម្បីការពារជីវិតអ្នក”

# លេខទូរស័ព្ទដែលត្រូវហៅ បន្ទាន់

*ករណីសង្ស័យគ្រុនផ្តាសាយថ្មី A/H1N1 :
១១៥ / ០១២ ៤៨៨ ៩៨១ / ០៨៩ ៦៦៩ ៩៦៧។
*មណ្ឌលកែប្រែអ្នកញៀនគ្រឿងញៀន :
០១២ ៨១២ ១១៧ / ០១៥ ៨៩៣ ៩៩៩។
*រថយន្តសង្គ្រោះបន្ទាន់ :
-ភ្នំពេញ ០២៣ ៧២៤ ៨៩១។ -សៀមរាប ០៦៣ ៧៦១ ១១៩។
*មជ្ឈមណ្ឌលផ្តល់ឈាម :
០២៣ ២១៥ ៩៤៩។

## ល្បែងកំសាន្ត

រកផ្លូវ

សូមប្រិយមិត្តជួយស្វែងរកផ្លូវឱ្យបុរសទៅកាន់ប្រាសាទដ៏ស្កុកស្កម្មនេះផង !



Photo : DR

## ការងារប្រចាំខែ

- ថ្ងៃទី០១ កុម្ភៈ : បើកវគ្គសិក្សាថ្មីរយៈពេលមួយឆ្នាំអំពីផ្នែកកសិកម្មក្នុងការចិញ្ចឹមសត្វ និងដាំបន្លែនៅមណ្ឌលគ្រាប់នៅខេត្តពោធិ៍សាត់ ភូមិភាគកាតូលិកបាត់ដំបង។
- ថ្ងៃទី០១ កុម្ភៈ : ប្រជុំអន្តរនិកាយណែនាំដោយលោកម៉េង ហុង រៀបចំឡើងនៅព្រះសហគមន៍កំពង់ចាម។
- ថ្ងៃទី០១-០៨ កុម្ភៈ : ប្រធានក្រុមយុវជន ០៦នាក់ ដែលមកពីភូមិភាគទាំងបី ទៅចូលរួមអធិដ្ឋានតេសេពិសេសនៅប្រទេសហ្វីលីពីន។
- ថ្ងៃទី០២ កុម្ភៈ : សំណាក់ធម៌ក្រុមបូជាចារ្យ រៀបចំឡើងនៅព្រះសហគមន៍សន្តយ៉ូសែប ហៅផ្សារតូច រាជធានីភ្នំពេញ។
- ថ្ងៃទី០២-០៥ កុម្ភៈ : សន្និបាតប្រចាំឆ្នាំ អ្នកអប់រំជំនឿរៀបចំឡើងនៅព្រះសហគមន៍កាតូលិកបាត់ដំបង។
- ថ្ងៃទី០៣-០៧ កុម្ភៈ : យកធាតុសន្តយ៉ូហាន ម៉ារី វីយ៉ាណេ មកតម្កល់នៅព្រះសហគមន៍ផ្សារតូច ព្រមទាំងអធិដ្ឋានពិសេសសម្រាប់ឆ្នាំបូជាចារ្យ និងរិះគិតពីជីវិតរបស់សន្តយ៉ូហាន ម៉ារី វីយ៉ាណេ។
- ថ្ងៃទី០៧ កុម្ភៈ : បរិច្ចាគឈាមនៅព្រះសហគមន៍ព្រះកុមារយេស៊ូបឹងទំពន់ ក្រុងភ្នំពេញ។
- ថ្ងៃទី១៤ កុម្ភៈ : អភិបូជាពិសេសដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំចិន វៀតណាម រៀបចំធ្វើឡើងនៅព្រះសហគមន៍វត្តចំប៉ា។
- ថ្ងៃទី១៤ កុម្ភៈ : អភិបូជាពិសេសដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំចិន វៀតណាម រៀបចំធ្វើឡើងនៅព្រះសហគមន៍អរិយក្សត្រ។
- ថ្ងៃទី១៧ កុម្ភៈ : ពិធីរោយផេះនៅព្រះសហគមន៍ព្រះកុមារយេស៊ូបឹងទំពន់នាពេលល្ងាច។
- ថ្ងៃទី១៧ កុម្ភៈ : ពិធីរោយផេះធ្វើឡើងនៅព្រះសហគមន៍ផ្សារតូច។
- ថ្ងៃទី១៧-១៩ កុម្ភៈ : ប្រជុំគណៈកម្មការអន្តរភូមិភាគអំពីរការរៀបចំអភិបូជានៅនិវេសនដ្ឋានលោកអភិបាលកាតូលិកភូមិភាគភ្នំពេញ។
- ថ្ងៃ២១ កុម្ភៈ : ពិធីជំហានទី២ ឬជ្រមុជទឹកដែលមានគ្រីស្តបរិសទ័មកពីព្រះសហគមន៍ផ្សេងៗ ធ្វើឡើងនៅព្រះសហគមន៍ផ្សារតូច ក្រោមអធិបតីភាពរបស់លោកអភិបាលថ្មី ភូមិភាគភ្នំពេញអូលីវីយេ។
- ថ្ងៃទី២៤ កុម្ភៈ : ប្រជុំទីប្រឹក្សារបស់លោកអភិបាលភូមិភាគកំពង់ចាម។